គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា

# សៀវភៅណែនាំស្តីពីការធ្វើផែនការបណ្តុះបណ្តាល

- តើអ្វីទៅជាការធ្វើផែនការបណ្តុះបណ្តាល ?
- ដំណាក់កាលទាំង៤នៃការធ្វើផែនការបណ្តុះបណ្តាល
- ដំណាក់កាលទី១: កំណត់ពីតម្រូវការ និងគោលបំណងនៃការបណ្តុះបណ្តាល
- ដំណាក់កាលទី២: បង្កើតផែនការបណ្តុះបណ្តាល
- ដំណាក់កាលទី៣: បង្កើតវគ្គបណ្តុះបណ្តាល
- ដំណាក់កាលទី៤: បង្កើតឯកសារបណ្តុះបណ្តាល

# មាតិកា

សន្ទានុក្រម ........................................................................ ៣

ផែនការបណ្តុះបណ្តាលជាអ្វី? ........................................................ ៤

ដំណាក់កាលទាំង៤នៃការធ្វើផែនការបណ្តុះបណ្តាល .................................. ៦

ដំណាក់កាលទី១ៈ កំណត់ពីតម្រូវការ និងគោលបំណងនៃការបណ្តុះបណ្តាល ...... ៧

ដំណាក់កាលទី២ៈ បង្កើតផែនការបណ្តុះបណ្តាល.................................. ១១

ដំណាក់កាលទី៣ៈ បង្កើតវគ្គបណ្តុះបណ្តាល......................................២០

ដំណាក់កាលទី៤ៈ បង្កើតឯកសារបណ្តុះបណ្តាល .................................. ៤០

ឯកសារយោង........................................................................ ៥៩

# សន្ទានុក្រម

| | |
|---|---|
| អ្នករៀបចំវគ្គបណ្តុះបណ្តាល | ជាអ្នកដែលបង្កើតកម្មវិធីបណ្តុះបណ្តាលដោយផ្អែកលើការប៉ាន់ប្រមាណពីការតម្រូវការបណ្តុះបណ្តាល និងផែនការបណ្តុះបណ្តាល ដែលរួមមានការសរសេរពីគោលបំណងនៃការរៀន ការបង្កើតសកម្មភាពនៃការរៀន ផែនការមេរៀន និងឧបករណ៍ជំនួយក្នុងការរៀន |
| កម្មវិធីសិក្សា | ជាឯកសារដែលរួមមានគោលបំណងនានា មេរៀន ប្លង់មេរៀន និងវិធីសាស្ត្រនៃការបណ្តុះបណ្តាល ឬការអប់រំ |
| អ្នកសម្របសម្រួល | ជាវិធីសាស្ត្រមួយដែលប្រើប្រាស់បទឧទ្ទេសនាមតិចតួច ហើយសម្របសម្រួលនូវសកម្មភាពនានារបស់សិក្ខាកាម ព្រមទាំងស្វែងរកគន្លឹះនៃការរៀន |
| សម្ភារៈ/ឧបករណ៍ឧទ្ទេស | ឧបករណ៍ និងសម្ភារៈដែលត្រូវបានប្រើប្រាស់សម្រាប់ការសិក្សារៀនសូត្រដូចជា ផ្លាស្ទិចថ្លា ស្លែសម្រាប់បង្ហាញ ប្រដាប់ ឬម៉ាស៊ីនបញ្ចាំងពន្លឺ (projector) គេហទំព័រណែនាំ (instructional web pages) និងកាសែតថតវីដេអូ |
| វិធីសាស្ត្របណ្តុះបណ្តាល | ជាវិធីសាស្ត្រនានាដែលអ្នករៀបចំវគ្គបណ្តុះបណ្តាលកំណត់ថានឹងបង្កើតបរិយាកាសរៀនសូត្រដ៏មានប្រសិទ្ធិភាពដូចជា បទឧទ្ទេសនាម ករណីសិក្សា និង ការពិសោធន៍ |
| ម៉ូឌុល (module) | ជាការប្រមូលផ្តុំនូវជំពូកនានាដែលទាក់ទងគ្នានៅក្នុងវគ្គមួយ |
| ក្រុមការងារគម្រោង | មានក្រុមការងារ អ.វ.ម និងអ្នកជំនាញការចៃកា |
| គ្រូឧទ្ទេស | ជាពាក្យដែលគេប្រើមានន័យថាជាគ្រូ ឬអ្នកណែនាំ |
| វគ្គបណ្តុះបណ្តាល | ជាការប្រមូលផ្តុំនៃប្រធានបទ និងសកម្មភាពដែលទាក់ទងនឹងគោលបំណងវគ្គ |
| ការបង្កើតវគ្គបណ្តុះបណ្តាល | ជាការរៀបចំ និងការបង្កើតនូវប្រព័ន្ធ និងកម្មវិធីបណ្តុះបណ្តាល |

# 1 តើផែនការបណ្តុះបណ្តាលជាអ្វី?




**ការធ្វើផែនការ** គឺជាដំណាក់កាលទី១នៃវដ្តនៃការគ្រប់គ្រងវគ្គបណ្តុះបណ្តាល ។ នៅដំណាក់កាលធ្វើផែនការនេះ ត្រូវបានចែកចេញជា២ៈ

ទី១ៈ ការប៉ាន់ប្រមាណពីតម្រូវការនៃការបណ្តុះបណ្តាល (TNA) និង

ទី២ៈ ការធ្វើផែនការបណ្តុះបណ្តាល ។

នៅក្នុងឯកសារនេះ នឹងពិភាក្សាអំពីផែនការបណ្តុះបណ្តាល ។

## និយមន័យ



" ***ការធ្វើផែនការបណ្តុះបណ្តាល*** " ត្រូវកំណត់អំពីតម្រូវការបណ្តុះបណ្តាល គោលបំណង និងលទ្ធផល ព្រមទាំងវិធីសាស្ត្រក្នុងការសម្រេចបាននូវគោលបំណង និងលទ្ធផលទាំងនេះដោយផ្អែកលើលទ្ធផលនៃការប៉ាន់ប្រមាណពីតម្រូវការបណ្តុះបណ្តាល ។ ការធ្វើផែនការបណ្តុះបណ្តាលនេះនិយាយអំពី បុព្វហេតុនៃភាពខ្វះខាត តើស្តង់ដាក្នុងការអនុវត្តន៏កម្រិតណាដែលមិនទាន់មាន និងនរណាជាក្រុមគោលដៅ ។ ផែនការនេះក៏ណែនាំបន្ថែមទាក់ទងនឹងមធ្យោបាយនៃការវាយតម្លៃទៅលើយុទ្ធសាស្ត្រនានាដែលបានស្នើឡើង ទាក់ទងនឹងរបៀបគ្រប់គ្រង និងពេលវេលាដែលត្រូវធ្វើ ។

ការធ្វើផែនការបណ្តុះបណ្តាលជាមូលដ្ឋានគ្រឹះនៃកម្មវិធីបណ្តុះបណ្តាលដែលមានប្រសិទ្ធិភាព ។ ការធ្វើផែនការធ្វើឱ្យការខិតខំប្រឹងប្រែង និងធនធានរបស់យើងសម្រេចបាននូវលទ្ធផលមួយ ។ ឯកសារដែលបានពីដំណាក់កាលនេះជាផែនការបណ្តុះបណ្តាលជាលាយលក្ខ័អក្សរដែលនឹងត្រូវបញ្ជូនទៅគ្រប់សមាជិកគម្រោង និងមន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃដើម្បីស្នើសុំការអនុម័ត ។ នៅពេលដែលបានអនុម័តហើយ ផែនការនេះនឹងត្រូវបានអនុវត្តន៏ដោយសមាជិកក្រុមការងារគម្រោងដើម្បីណែនាំផ្លូវដល់ការបង្កើតវគ្គបណ្តុះបណ្តាលរបស់ពួកគេជាលើកដំបូង ។

ផែនការបណ្តុះបណ្តាលជាគន្លឹះដើម្បីឱ្យវគ្គបណ្តុះបណ្តាលមានប្រសិទ្ធិភាពនឹងកំណត់អំពី អ្វី នរណា នៅពេលណា នៅកន្លែងណា ដោយរបៀបណា និងហេតុអ្វីបានជារៀបចំវគ្គបណ្តុះបណ្តាល ។ វគ្គបណ្តុះបណ្តាលដែលមានប្រសិទ្ធិភាពតម្រូវឱ្យមានរូបភាពច្បាស់លាស់ពីរបៀបដែលសិក្ខាកាមយកជំនាញបច្ចេកទេស និងចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្ត ។

# 2 ដំណាក់កាលទាំង៤នៃការធ្វើផែនការបណ្តុះបណ្តាល

## ដំណាក់កាលទាំង៤:

ដំណើរការនៃ " ការធ្វើផែនការបណ្តុះបណ្តាល " អាចត្រូវបានចែកចេញជា៤ដំណាក់កាល:

ដំណាក់កាលទី១: កំណត់ពីតម្រូវការ និងគោលបំណងនៃវគ្គបណ្តុះបណ្តាល

ដំណាក់កាលទី២: បង្កើតផែនការបណ្តុះបណ្តាល

ដំណាក់កាលទី៣: បង្កើតវគ្គបណ្តុះបណ្តាល និង

ដំណាក់កាលទី៤: បង្កើតឯកសារបណ្តុះបណ្តាល

- កំណត់ពីកិរិតនៃស្ថានភាពបច្ចុប្បន្ន
- បង្កើតចក្ខុវិស័យសម្រាប់ស្ថានភាពដែលចង់បាន
- កំណត់ និងធ្វើអាទិភាពពីតម្រូវការបណ្តុះបណ្តាល
- កំណត់ពីគោលបំណងនៃវគ្គបណ្តុះបណ្តាល

- កែប្រែគោលបំណងនៃវគ្គទៅជាសមាសភាពជាក់ស្តែងនៃវគ្គ
- បង្កើតផែនការបណ្តុះបណ្តាល

- បង្កើតវគ្គបណ្តុះបណ្តាលកម្មវិធីសិក្សា និងសង្ខេបមេរៀន
- កំណត់វិធីសាស្ត្រណែនាំ និងសម្ភារៈ/ឧបករណ៍ឧទ្ទេស និងឯកសារ

- បង្កើតឯកសារមេរៀនដោយផ្អែកលើកម្រិតនៃតម្រូវការរបស់សិក្ខាកាម

# 3 ដំណាក់កាលទី១ៈ កំណត់ពីតម្រូវការ និងគោលបំណងនៃវគ្គបណ្តុះបណ្តាល

ដំណាក់កាលទី១នៃការធ្វើផែនការបណ្តុះបណ្តាលគឺត្រូវកំណត់អំពីគោលបំណងនៃវគ្គដោយផ្អែកលើតម្រូវការបណ្តុះបណ្តាលដែលបានកំណត់ដោយការប៉ាន់ប្រមាណពីតម្រូវការបណ្តុះបណ្តាល(TNA) ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងសមាជិកក្រុមការងារគម្រោងនឹងធ្វើការកំណត់អាទិភាពលើតម្រូវការបណ្តុះបណ្តាលក្នុងចំណោមតម្រូវការបណ្តុះបណ្តាលនានាដែលបានរកឃើញដោយស្របតាមគោលនយោបាយ និងការណែនាំរបស់ក្រសួងមហាផ្ទៃ។



ដំណាក់កាលនានាក្នុងការកំណត់ពីតម្រូវការបណ្តុះបណ្តាល និងគោលបំណងនៃការបណ្តុះបណ្តាលត្រូវបានប្រព្រឹត្តទៅដូចខាងក្រោមៈ




គំនូសតាងទី១ៈ ដំណាក់កាលនានាត្រូវអនុវត្តដើម្បីកំណត់គោលបំណង និងតម្រូវការបណ្តុះបណ្តាល

ការវិភាគ
ស្ថានភាព

ដើម្បីកំណត់នូវកម្រិតស្ថានភាពបច្ចុប្បន្ន ខ្សែបន្ទាត់សមត្ថភាព ចំណេះដឹង អាកប្បកិរិយា និង ជំនាញ **(KAS)** ដែលបានធ្វើការប៉ាន់ប្រមាណនៅពេលធ្វើTNA ។ KASជាប្រភេទនានានៃប្រព័ន្ធចំណាត់ថ្នាក់មួយ (សូមមើលតារាងនៅទំព័របន្ទាប់) ដែលជាវិធីមួយក្នុងការរៀបចំកិច្ចការនានាដែលជាន់គ្នានៅថ្នាក់ស្រុក ។ ព័តិមានអំពីស្ថានភាពបច្ចុប្បន្នទៅលើប្រធានបទណាមួយដែលបានកំណត់អាចត្រូវបានប្រមូលបានតាមរយៈការធ្វើអង្កេត ការធ្វើសម្ភាសន៍ ការពិភាក្សាក្រុម ការសង្កេត ទិន្នន័យដែលបានមកពីប្រភពផ្សេងៗ ការធ្វើសិក្ខាសាលា និងការពិគ្រោះយោបល់ជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។ កម្រិតនៃការយល់ដឹងរបស់ក្រុមគោលដៅសម្រាប់ស្ថានភាពបច្ចុប្បន្នត្រូវបានកំណត់តាមរយៈការធ្វើ TNA ។

បង្កើតចក្ខុវិស័យ
សម្រាប់
ស្ថានភាពដែលចង់បាន

បន្ទាប់ពីបានដឹងពីស្ថានភាពភាពបច្ចុប្បន្នទាក់ទងនឹងចំណេះដឹង អាកប្បកិរិយា និងជំនាញទៅលើប្រធានបទដែលគេបានកំណត់រួចហើយ គេត្រូវបង្កើតនូវស្ថានភាពមួយដែលគេចង់បាន (ឧទាហរណ៍ ក្រសួងមហាផ្ទៃចាប់ផ្តើមជំរុញដល់វិមជ្ឈការ និងវិសហមជ្ឈការ) ដោយមានការប្រឹក្សាយោបល់ជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងសមាជិកក្រុមការងារគម្រោង ។ ដើម្បីបំពេញនូវចំណុចខ្វះខាតរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលចង់បាន សិក្ខាកាមចាំបាច់ត្រូវបង្កើនសមត្ថភាពទាក់ទងនឹងចំណេះដឹង ជំនាញ និងអាកប្បកិរិយា។ ដំណើរការនេះផ្ទៀងផ្ទាត់ថាតើវគ្គបណ្តុះបណ្តាលជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការបំពេញនូវចំណុចខ្វះខាតនេះឬក៏អត់ ។

កំណត់
និងធ្វើអាទិភាព
ពីតម្រូវការ
បណ្តុះបណ្តាល

បន្ទាប់ពីបានបង្កើតនូវស្ថានភាពដែលចង់បាន និងបានបញ្ជាក់នូវស្ថានភាពបច្ចុប្បន្នអំពីជំនាញKAS រួចហើយ គេធ្វើការកំណត់អំពីតម្រូវការបណ្តុះបណ្តាល និងធ្វើអាទិភាពដោយពិគ្រោះយោបល់ជាមួយក្រុមការងារគម្រោងដោយយោងទៅលើលទ្ធផលនៃការធ្វើTNA ។ បន្ទាប់មក ការធ្វើអាទិភាពពីតម្រូវការបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងដោយមន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ និងសមាជិកក្រុមការងារគម្រោងដោយធ្វើការពិចារណាទៅលើការណែនាំ និងគោលនយោបាយរបស់ក្រសួងមហាផ្ទៃ ។

កំណត់គោលបំណង
នៃការបណ្តុះបណ្តាល

គោលបំណងនៃវគ្គបណ្តុះបណ្តាលត្រូវបានកំណត់បន្ទាប់ពីបានកំណត់ និងធ្វើអាទិភាពពីតម្រូវការបណ្តុះបណ្តាល ។ នៅក្នុងដំណើរការនេះ ចំណាត់ថ្នាក់នៃចំណេះដឹង ជំនាញ(KAS) និងអាកប្បកិរិយាត្រូវបានគេប្រើប្រាស់ម្តងទៀតដើម្បីកំណត់ពីគោលបំណង ។ ប្រព័ន្ធចំណាត់ថ្នាក់នេះ អាចត្រូវបានគេ

ចាត់ទុកថាជា" គោលដៅនៃដំណើរការវគ្គ" ។ ន័យផ្សេងទៀតគឺថា សិក្ខាកាមគួរទទួលបាននូវជំនាញ ចំណេះដឹង និងអាកប្បកិរិយាថ្មីៗបន្ទាប់ពីទទួលបានការបណ្តុះបណ្តាល ។ ចំណាត់ថ្នាក់នីមួយៗអាចត្រូវបានធ្វើឡើងដោយសារសកម្មភាពជាក់លាក់នានា ។ តារាងទី១រួមមានពាក្យគន្លឹះដែលទាក់ទងទៅនឹងសកម្មភាពទាំងនោះ និងការរៀបរាប់អំពីប្រភេទនីមួយៗនៃKAS ដែលត្រូវបានបង្ហាញក្នុងតារាងទី១ ។

### តារាងទី១: គោលបំណងនៃការបណ្តុះបណ្តាល ឬប្រព័ន្ធចំណាត់ថ្នាក់

គោលបំណង នៃ ការបណ្តុះបណ្តាល

| ប្រភេទ | ពិពណ៌នា |
|---|---|
| ចំណេះដឹង (ជំនាញផ្នែកស្មារតី) | វាទាក់ទងនឹងចំណេះដឹង និងបញ្ញា ។ វារួមមាន ការរកនឹក ឬការទទួលស្គាល់នូវហេតុការណ៍ជាក់លាក់ បែបបទនីតិវិធី និងទស្សនៈដែលទាក់ទងនឹងសមត្ថភាពខាងបញ្ញា និងជំនាញ ។ មានចំណាត់ថ្នាក់ចំនួន០៦ដែលត្រូវបានដាក់តាមលំដាប់លំដោយខាងក្រោម ដោយចាប់ផ្តើមពីភាពងាយស្រួលជាងគេ ដល់ភាពលំបាកជាងគេ ។ ចំណាត់ថ្នាក់ទាំងនេះ អាចត្រូវបានគេគិតថាលំបាក ។ |
| | ១. **ចំណេះដឹង:** ការរកនឹកនូវទិន្នន័យ ឬព័ត៌មាន<br>២. **កម្រិតនៃការយល់:** យល់ពីអត្ថន័យ ការបកប្រែអំពីការណែនាំ និងបញ្ហា និងការបកប្រែផ្សេងៗទៀត<br>៣. **ទម្រង់បែបបទ:** ប្រើតាមស្ថានភាពថ្មី<br>៤. **ការវិភាគ:** បែងចែកឯកសារ ឬទស្សនៈជាចំណែកៗដើម្បីឱ្យគេយល់ពី រចនាសម្ព័ន្ធរបស់វា<br>៥. **ការសំយោគ:** បង្កើតរចនាសម្ព័ន្ធ ឬបែបទមួយដែលចេញពីធាតុផ្សេងៗគ្នា ។ បញ្ចូលធាតុនានាជាមួយគ្នាដើម្បីបង្កើតបានជារចនាសម្ព័ន្ធមួយដែលបង្ហាញ ពីអត្ថន័យ ឬរចនាសម្ព័ន្ធថ្មី<br>៦. **ការវាយតម្លៃ:** ធ្វើការវាយតម្លៃទៅលើសម្ភារៈ ឬមតិយោបល់ |
| | **ពាក្យគន្លឹះ :** ការអោយនិយមន័យ ការកំណត់ ចំណេះដឹង បញ្ជី ចំណងជើង ទទួលស្គាល់ កម្រិតនៃការយល់ បញ្ជាក់អោយច្បាស់ ទទួល សង្ខេប យកទៅអនុវត្ត ចង្អុលបង្ហាញ រកឃើញ រៀបចំ ផលិត វិភាគ ធ្វើចំណាត់ថ្នាក់ ចងក្រង ធ្វើផែនការ ចាត់ចែង សរសើរ សន្និដ្ឋាន រិះគន់ ពិពណ៌នា |
| អាកប្បកិរិយា (ចេញពីអារម្មណ៍) | ផ្នែកនេះសំដៅទៅលើចរិកលក្ខណៈដូចជា អារម្មណ៍ ការឱ្យតម្លៃ ការសរសើរ ចំណង់ចំណូលចិត្ត ការលើកទឹកចិត្ត និងអាកប្បកិរិយា ។ មាន៥ចំណាត់ថ្នាក់ចម្បងៗដែលត្រូវបានគេរៀបរាប់ខាងក្រោម មានតាំងពីឬកពារសាមញ្ញបំផុត រហូតដល់ ឬកពារស៊ាំញ៉ាំបំផុត ។ |

| | |
|---|---|
| | ១- **ការទទួលចំណេះដឹង:** ការដឹង ការចង់ឮ ការយកចិត្តទុកដាក់<br>២- **ការឆ្លើយតបរបស់សិក្ខាកាម:** ការចូលរួមយ៉ាងសកម្ម ។ ចូលរួម ហើយប្រតិកម្មនូវបាតុភូតជាពិសេសណាមួយ<br>៣- **ការឱ្យតម្លៃ:** តម្លៃនៃមនុស្សម្នាក់ផ្សារភ្ជាប់ទៅនឹងកម្មវត្ថុ បាតុភូត ឬអត្តចរិត<br>៤- **ការរៀបចំ:** រៀបចំធ្វើការឱ្យតម្លៃ<br>៥- **បង្កើតតម្លៃ:** មានប្រព័ន្ធតម្លៃមួយដែលគ្រប់គ្រងអត្តចរិតរបស់មនុស្ស |
| | **ពាក្យគន្លឹះ:** បង្កើន ផ្តល់អនុសាសន៍ ជ្រើសរើស លើកទឹកចិត្ត ឆ្លើយ ជួយ ចងក្រង បញ្ជាក់ឡើងវិញ ពិភាក្សា បំពេញភារកិច្ច អនុវត្ត រាយការណ៍ បញ្ចប់ គូសបញ្ជាក់ រៀបចំ បង្កើត |
| **ជំនាញ**<br>(ផ្នែករូបរាងខាងក្រៅ) | ផ្នែកនេះរួមមានចលនានៃរូបរាងកាយ ការសម្របសម្រួល និង ការប្រើប្រាស់ជំនាញ ។ កាបង្កើតជំនាញទាំងនេះទាមទារឱ្យមានការអនុវត្ត និងមានការវាស់វែងល្បឿន ភាពជាក់ច្បាស់ ចម្ងាយ នីតិវិធីនានា ឬ បច្ចេកទេសក្នុងការប្រតិបត្តិ ។ មានប្រភេទចំណាត់ថ្នាក់ចំនួន៧ ដែលត្រូវបានគេរៀបរាប់ខាងក្រោមពីអត្តចរិត/ ឬកពារងាយស្រួលបំផុត ទៅស្មុគស្មាញបំផុត: |
| | ១- **ការយល់ដឹង:** អាចប្រើវិញ្ញាណដើម្បីនាំផ្លូវសកម្មភាពនានា<br>២- **ការត្រៀមខ្លួន:** ត្រៀមខ្លួនដើម្បីប្រតិកម្ម ។ មានការត្រៀមទាំងស្មារតី រូបរាង និង អារម្មណ៍<br>៣- **ការឆ្លើយតបរបស់សិក្ខាកាម:** ដំណាក់កាលដំបូងក្នុងការរៀនជំនាញស្មុគស្មាញមានការត្រាប់តាម និងការសាកល្បង និងកំហុសនានា ។<br>៤- **យន្តការ:** វាជាដំណាក់កាលបន្ទាប់ក្នុងការរៀននូវជំនាញស្មុគស្មាញមួយ ។<br>៥- **សកម្មភាពស្មុគស្មាញ:** ការបំពេញការងារដោយជំនាញដែលទាក់ទងនឹងចលនាស្មុគស្មាញ<br>៦- **ការកែសម្រួល:** ជំនាញត្រូវបានបង្កើតបានយ៉ាងល្អ ហើយមនុស្សម្នាក់ៗ អាចកែតម្រូវបែបបទនៃចលនាឱ្យស្របនឹងតម្រូវការពិសេស ។<br>៧- **ការបង្កើត:** ការបង្កើតបែបបទថ្មីដើម្បីឱ្យស្របនឹងស្ថានភាពពិសេសណាមួយ |
| | **ពាក្យគន្លឹះ:** បែងចែក ទាក់ទង ផ្តួចផ្តើម បង្កើត ផ្តុំ ពន្យល់ ប្រតិកម្ម បង្ហាញ និយាយ ឆ្លើយតប ប្រតិបត្តិ រៀបចំ ពិភាក្សា គ្រប់គ្រង ប្រើប្រាស់ ផលិត តាមដាន វាស់វែង សម្របសម្រួល មានដើមកំណើត បញ្ចូលគ្នា សាងសង់ |

(ប្រភព: Bloom, B. S. (1956). *Taxonomy of Educational Objectives, Handbook I: The Cognitive Domain*)

# 4 ដំណាក់កាលទី២ៈ បង្កើតផែនការបណ្តុះបណ្តាល

ដំណាក់កាលទី២នៃការធ្វើផែនការបណ្តុះបណ្តាលគឺត្រូវបង្កើតផែនការបណ្តុះបណ្តាលដែលរួមមានៈ (១) ចំណងជើងវគ្គ (២) ទំហំនៃវគ្គ (៣) ក្រុមគោលដៅ (៤) ប្រធានបទគន្លឹះ និងសកម្មភាពវគ្គ (៥) ការប៉ាន់ប្រមាណពីពេលវេលានៃការបង្កើតផែនការ (៦) ធនធានដែលត្រូវការ (៧) រយៈពេលសម្រាប់វគ្គនីមួយៗ និង (៨) ថវិកា ។








ផែនការបណ្តុះបណ្តាលមានគោលបំណងជាគន្លឹះពីរៈ ជម្រុញឱ្យមានការខិតខំប្រឹងប្រែង និងជួយធ្វើការសម្រេចចិត្តទាក់ទងនឹងការបណ្តុះបណ្តាល ។ ផែនការបណ្តុះបណ្តាលអាចក្រើនរំលឹកអ្នកចំពោះបញ្ហា និងឧបសគ្គនានា ។ ឧទាហរណ៍ៈ ផែនការជំរុញអោយអ្នកគិតថានឹងត្រូវធ្វើអ្វី និងធនធានអ្វីខ្លះដែលអ្នកត្រូវការ ។ ផែនការបណ្តុះបណ្តាលគួរមាននូវធាតុនានាដូចខាងក្រោមនេះ ។



**គំនូសតាងទី២ៈ ប្លង់នៃផែនការបណ្តុះបណ្តាល**

១. ចំណងជើងវគ្គ
២. និយមន័យនៃទំហំនៃវគ្គ
៣. កំណត់ក្រុមគោលដៅ
៤. កំណត់ប្រធានបទ និងសកម្មភាពវគ្គ
៥. ប៉ាន់ស្មានពីពេលវេលាសម្រាប់បង្កើតផែនការ
៦. កំណត់ធនធានដែលត្រូវការ
៧. រយៈពេលសម្រាប់វគ្គ
៨. គម្រោងថវិកាសម្រាប់វគ្គ

ឧទាហរណ៍នៃប្លង់ផែនការវគ្គ

## ១. ចំណងជើងវគ្គ

វគ្គបណ្តុះបណ្តាលទាំងឡាយគួរមានឈ្មោះដើម្បីឆ្លុះបញ្ចាំងនូវគោលបំណងរបស់វា ។

## ២. និយមន័យនៃទំហំវគ្គ

ទំហំវគ្គគួរត្រូវបានកំណត់ទាក់ទងនឹងព្រំដែននៃខ្លឹមសារ ។ ឧទាហរណ៍ៈ ទំហំនៃវគ្គប្រាកដជាបង្ហាញពីរូបភាពនៃគម្រោង ។

**តារាងទី២ៈ ឧទាហរណ៍ទាក់ទងនឹងទំហំវគ្គ**

| គំរូសំនួរ | គំរូចម្លើយ |
|---|---|
| ហេតុអ្វីបានជាត្រូវការការបណ្តុះបណ្តាល? | ដើម្បីកែលម្អកម្រិតចំណេះដឹងទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការរបស់មន្ត្រីរាជការ |
| តើគោលដៅវគ្គជាអ្វី? | ដើម្បីយល់ពីគោលនយោបាយរបស់រដ្ឋាភិបាល (វិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន) |
| នៅពេលណាសិក្ខាកាមឈប់ត្រូវការវគ្គបណ្តុះបណ្តាលនេះ ? ហើយគេអាចធ្វើអ្វី? | ដើម្បីទទួលបាននូវជំនាញវិភាគសម្រាប់អនុវត្តច្បាប់រៀបចំអង្គការ ដែលនឹងត្រូវបានអនុម័តនាពេលខាងមុខ |
| ស្ថានភាពបែបណា? | នៅក្រោមលក្ខខណ្ឌការងារដែលមិនពិត |
| សមត្ថភាពកម្រិតណា? | ពួកគេចាំបាច់អាចនិយាយអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងមានទស្សនៈជារួមចំពោះការជំរុញដល់វិមជ្ឈការ និងវិសហមជ្ឈការ |
| តើមានអ្វីជាការបញ្ជាក់ | វិញ្ញាបនប័ត្រ និងកំណើននៃពិន្ទុពីតេស្តមុនវគ្គ និងតេស្តក្រោយវគ្គ |

## ៣. កំណត់ក្រុមគោលដៅ

ក្រុមគោលដៅ (សិក្ខាកាម) ជាមនុស្សដែលទទួលនូវវគ្គបណ្តុះបណ្តាល ។ ការកំណត់ក្រុមគោលដៅនេះគេគិតទៅលើ (១) កម្រិតចំណេះដឹង និងជំនាញនាពេលបច្ចុប្បន្នរបស់ពួកគេ (២) ចំណុចខ្វះខាតនៃចំណេះដឹង និងជំនាញ (៣) ចំណេះដឹង និងជំនាញដែលចាំបាច់ត្រូវទទួល (៤) មានមនុស្ស

ប៉ុន្មាននាក់ត្រូវការចំណេះដឹង និងជំនាញនេះ (៥) មានមនុស្សប៉ុន្មាននាក់ត្រូវការទទួលការណែនាំ (៦) តើអ្វីដែលគេត្រូវការទាក់ទងនឹងវេន ម៉ោង វប្បធម៌ ភាសា និងទីតាំងភូមិសាស្ត្រ ។

**តារាងទី៣ៈ ឧទាហរណ៍ទាក់ទងនឹងការកំណត់ក្រុមគោលដៅ**

គំរូនៃ
ប្លង់ផែនការវគ្គ

| គំរូសំណួរ | គំរូចម្លើយ |
|---|---|
| នរណាត្រូវទទួលការបណ្តុះបណ្តាល? | មន្ត្រីក្រសួងមហាផ្ទៃ (បុគ្គលិកអចិន្ត្រៃយ៍) |
| តើគេធ្វើការអោយក្រសួងមហាផ្ទៃប៉ុន្មានឆ្នាំហើយ? | មិនកំណត់ |
| តើគេបានដឹងអ្វីខ្លះរួចហើយពីប្រធានបទ? | យោងតាមការធ្វើអង្កេត ភាគច្រើនបានដឹងពីវិមជ្ឈការ និងវិសហមជ្ឈការ ។ តែទោះបីជាយ៉ាងណាក៏ដោយ ការយល់ដឹងនៅមានកម្រិត ។ |
| តើមានទាំងអស់គ្នា ឬមួយចំនួនដែលត្រូវការការបណ្តុះបណ្តាល? | មានមួយចំនួនដែលធ្វើការទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការត្រូវការវគ្គបណ្តុះបណ្តាល ។ ទោះបីជាយ៉ាងណាក៏ដោយ គេរំពឹងថាប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សដែលនឹងបង្កើតដោយក្រសួងមហាផ្ទៃ នឹងធ្វើឡើងសម្រាប់មន្ត្រីទាំងអស់ក្នុងរយៈពេលយូរ ។ |
| តើយើងកំណត់ថានរណាត្រូវការការបណ្តុះបណ្តាលដោយរបៀបម៉េច? | គោលនយោបាយនៃមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងលទ្ធផលនៃការពិគ្រោះយោបល់រវាងចៃកា និងជំនាញការចៃកា |
| តើមនុស្សប៉ុន្មាននាក់ត្រូវការការបណ្តុះបណ្តាល? នៅកន្លែងណា? | សិក្ខាកាមត្រូវបានកំណត់រួចហើយដោយក្រសួងមហាផ្ទៃ និងចៃកាមុនពេលអនុវត្តគម្រោងៈ<br>-មន្ត្រីរដ្ឋបាលជាន់ខ្ពស់ៈ ១២៥នាក់ x ២វគ្គ x ៤ឆ្នាំ<br>-មន្ត្រីអ.រ.ម ២៥នាក់ x ៤ដង x ៤ឆ្នាំ |
| តើវគ្គបណ្តុះបណ្តាលត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ឬជាកំហិត? | ជាកំហិត |
| តើយើងគួរធ្វើម៉េចទាក់ទងនឹងពេលវេលាការធ្វើដំណើរ និងថវិកា? | ការធ្វើដំណើរ ពេលវេលា និងថវិកានៃវគ្គបណ្តុះបណ្តាលនឹងត្រូវបានអនុវត្តជាដំណាក់កាល ដូចបានរៀបរាប់នៅក្នុងម៉ាទ្រិចនៃគម្រោង ។ |

| | |
|---|---|
| តើគេត្រូវការអ្វីមុនវគ្គ? | ចៃកា និងក្រសួងមហាផ្ទៃព្រមទទួលយកផែនការបណ្តុះបណ្តាលអោយស្របនឹងទិសដៅ និងគោលនយោបាយរបស់ក្រសួងមហាផ្ទៃ ។ |
| តើគេនឹងធ្វើអ្វីចំពោះចំណេះដឹងដែលទទួលបានពីវគ្គ? | គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការកំពុងត្រូវបានជំរុញ ជាពិសេសប្រសិនបើច្បាប់រៀបចំអង្គការត្រូវបានធ្វើបដិលេខ ។ |

## ៤. ការកំណត់ប្រធានបទគន្លឹះ និងសកម្មភាពវគ្គ

ប្រធានបទ និងសកម្មភាពសំខាន់ៗដែលគួរត្រូវដាក់បញ្ចូលនៅក្នុងវគ្គត្រូវបានគេហៅថា សមាសធាតុគន្លឹះ។ ឧទាហរណ៍: សកម្មភាពជាគន្លឹះសម្រាប់ PILAC1 មាន: (១) ការវិវឌ្ឍន៍នៃច្បាប់រៀបចំអង្គការ (២) គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង (៣) រដ្ឋបាលមូលដ្ឋាន ។ សកម្មភាពសំខាន់ៗជាវិធីសាស្ត្រដែលត្រូវបានគេបញ្ចូលនៅក្នុងវគ្គ ។ ឧទាហរណ៍: បទឧទ្ទេសនាម ករណីសិក្សាផ្អែកលើរឿងរ៉ាវជាក់ស្តែង ការពិភាក្សាក្រុម និងការធ្វើសិក្ខាសាលានានាដែលអាចអនុវត្តបាន ។

សំណួរគន្លឹះជួយបង្កើតឱ្យមានប្រធានបទគន្លឹះ ។ ដំណាក់កាលនៃការធ្វើវិភាគលើដំណើរការនៃការបង្កើតវគ្គបណ្តុះបណ្តាលនឹងធ្វើការកំណត់ប្រធានបទណាជាប្រធានបទសំខាន់ និងមានប្រយោជន៍ដល់ការកែលម្អកម្រិតចំណេះដឹង ឬប្រធានបទណាមួយដែលបាត់ពីបញ្ជី ។




### ការប៉ាន់ប្រមាណពីពេលវេលាក្នុងការបង្កើតផែនការបណ្តុះបណ្តាល

ពេលវេលាអាចជាធនធានដ៏សំខាន់ជាងគេបំផុតនៃអ្នកបង្កើតផែនការបណ្តុះបណ្តាល ។ វាហាក់ដូចជាមិនដែលគ្រប់គ្រាន់ទេសម្រាប់អ្នកបង្កើតផែនការបណ្តុះបណ្តាល ។ ការធ្វើកាសម្រេចចិត្តក្នុងការធ្វើផែនការបណ្តុះបណ្តាលអាស្រ័យលើពេលវេលាណាមួយក៏បានក្នុងចំណោមពេលវេលាទាំងពីរ: កាលបរិច្ឆេទដែលមិនអាចផ្លាស់ប្តូរបាន ឬក៏កាលបរិច្ឆេទដែលបានប៉ាន់ស្មាន។ កាលបរិច្ឆេទដែលមិនអាចផ្លាស់ប្តូរបាន នាំមកនូវការសម្រេចចិត្តណាមួយ រីឯកាលបរិច្ឆេទដែលបានប៉ាន់ស្មានចេញមកពីការសម្រេចចិត្តនៅពេលយើងធ្វើការបង្កើតវគ្គ ។

នៅពេលដែលការបណ្តុះបណ្តាលមានកាលបរិច្ឆេទដែលមិនអាចផ្លាស់ប្តូរបាន តារាងខាងក្រោមនេះ

ជួយអ្នកដើម្បីកំណត់អំពីពេលវេលាដែលអ្នកអាចចំណាយទៅលើដំណាក់កាលនីមួយៗ ។ កាលបរិច្ឆេទនៃវគ្គបណ្តុះបណ្តាលរបស់គម្រោងភីឡាក់ មានកំណត់នៅក្នុងតារាងម៉ាទ្រិចរបស់គម្រោង ។

**តារាងទី៤ៈ គំរូទាក់ទងនឹងការប៉ាន់ប្រមាណពេលវេលា**

| រាយមុខ | | ខ្លឹមសារ |
|---|---|---|
| ១. ការធ្វើផែនការបណ្តុះបណ្តាល | | ពេលវេលាដែលត្រូវការសម្រាប់ដំណាក់កាលនេះផ្អែកលើ ថាតើគំនិតនៃវគ្គច្បាស់ ប៉ុណ្ណា តើធនធានត្រូវបានពិភាក្សាឬអត់ តើពេលវេលាត្រូវបានកំណត់ឬអត់ ។ |
| ២. ការពិភាគ | | ការវិភាគរួមមានៈ ការវិភាគក្រុមគោលដៅ ការវិភាគកិច្ចការ ការវិភាគបរិយាកាសនៃការបណ្តុះបណ្តាល និងការវិភាគទៅលើរបាយការណ៍ ។ |
| ២.១ | ការវិភាគក្រុមគោលដៅ | ក្រុមគោលដៅដែលមកពីកន្លែងផ្សេងៗគ្នាចាំបាច់ត្រូវការម៉ោងបន្ថែម ។ បន្ថែមពេលវេលាធ្វើដំណើរទៅលើពេលវេលាដែលអ្នកបានប៉ាន់ប្រមាណ ។ |
| ២.២ | ការវិភាគកិច្ចការ | ពេលវេលាទាក់ទងការវិភាគនេះផ្អែកលើភាពងាយស្រួលទាក់ទងរវាងអ្នកជំនាញការ និងប្រជាពលរដ្ឋ ជាមួយនឹងអ្នកដែលយើងធ្វើការជាមួយ និងភាពរហ័សនៃការឆ្លើយតបរបស់ពួកគេមកលើឯកសារដែលយើងបានផ្តល់ឱ្យគេដើម្បី រំលឹក និងផ្តល់យោបល់ ។ បន្ថែមពេលវេលាសម្រាប់ការវិភាគក្រុមគោលដៅ ។ |
| ២.៣ | ការវិភាគ បរិយាកាសនៃការបណ្តុះបណ្តាល | ការវិភាគនេះជាទូទៅចំណាយពេលវេលាច្រើន ហើយជាញឹកញាប់វាលើកឡើងនូវសំនួរអំពីលទ្ធភាពធនធានដែលមាន រួមមានការកំណត់ លក្ខខណ្ឌដូចជា ទីតាំង និងមធ្យោបាយនៃវគ្គ ឧបករណ៍ និងប្រព័ន្ធផ្សព្វផ្សាយ លក្ខខណ្ឌនៃការចុះឈ្មោះ (កាតព្វកិច្ច ឬដោយស្ម័គ្រចិត្ត) ការផ្តល់ជូនសិក្ខាកាមនៅពេលបញ្ចប់វគ្គ និងការវាយតម្លៃ ។ |
| ២.៤ | ការវិភាគរបាយការណ៍ | ការវិភាគនេះរួមមានពេលវេលាដែលចំណាយទៅលើ ការប្រជុំគ្នាដើម្បីពិភាក្សាពីលទ្ធផលនៃការវិភាគខាងលើ |
| ៣. ការបង្កើតគោលបំណង | | បង្កើតគោលបំណងនានាដោយអ្នកបង្កើតផែនការបណ្តុះ បណ្តាល |

| | |
|---|---|
| | (ក្រុមការងារ អ.វ.ម និងអ្នកជំនាញការចៃកា) |
| ៤. ការបង្កើតវគ្គ | លទ្ធផលនៃដំណាក់កាលនេះគឺការបង្កើតវគ្គ និងការជ្រើសរើសវិធីសាស្ត្រក្នុងការបណ្តុះបណ្តាល និងប្រព័ន្ធផ្សព្វផ្សាយ គួរឆ្លើយតបនឹងសេចក្តីត្រូវការរបស់ក្រុមគោលដៅ |
| ៥. ការបង្កើតសម្ភារៈបណ្តុះបណ្តាល | ដំណាក់កាលនេះអាចចំណាយពេលច្រើន បើសិនជាយើងបង្កើតសម្ភារៈបណ្តុះបណ្តាលជាច្រើនដូចជា ការសរសេរអត្ថបទ ការសំដែង ការបោះពុម្ព និងការផលិត ។ ការបង្កើតសម្ភារៈទាំងនេះទាក់ទងនឹងការបង្កើត ការរៀបចំទម្រង់ ការបោះពុម្ព និងការរៀបចំឯកសារបណ្តុះបណ្តាល ការធ្វើលំហាត់ សកម្មភាព និងឯកសារគាំទ្រសកម្មភាព ។ |
| ៦. ការកែតម្រូវ | បន្ថែមពេលវេលាសម្រាប់ការបន្ថែមតិចតួច និងការធ្វើ បច្ចុប្បន្នភាព |

គំរូនៃប្លង់ផែនការ បណ្តុះបណ្តាល

### ៦. ការកំណត់ធនធានដែលត្រូវការ

ផែនការគម្រោងត្រូវមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលត្រូវការសម្រាប់គ្រប់ដំណាក់កាលនៃវគ្គរួមមាន ការរចនា ការអនុវត្ត ការតាមដាន និងការវាយតម្លៃ ។ គេបញ្ចូលសមាជិកក្រុមការងារគម្រោង អ្នកជំនាញការ ឧបករណ៍/សម្ភារៈ មធ្យោបាយ និងសេវា ។ សេវាអាចរួមមានការកក់ទីកន្លែងបើកវគ្គ និងកន្លែងស្នាក់នៅ អាហារ និងការបោះពុម្ព ។

**តារាងទី៥ៈ ការកំណត់ធនធានដែលត្រូវការ**

| គំរូសំណួរ | គំរូចម្លើយ |
|---|---|
| តើត្រូវការមធ្យោបាយអ្វីខ្លះសម្រាប់អនុវត្តវគ្គបណ្តុះបណ្តាល? | ក្រសួងមហាផ្ទៃមានសាលប្រជុំដែលអាចដាក់មនុស្សប្រមាណ៣០នាក់ និង១០០នាក់ ។ មានជម្រើសផ្សេងទៀតដូចជា សណ្ឋាគារ និងមជ្ឈមណ្ឌលសម្រាប់សហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ។ |
| តើត្រូវការសម្ភារៈ/ឧបករណ៍អ្វីខ្លះ ? តើមានសម្ភារៈ/ឧបករណ៍ទាំងនោះសម្រាប់ថ្ងៃបណ្តុះបណ្តាលទេ? | កំព្យូទ័រ ម៉ាស៊ីនបញ្ចាំងពន្លឺ ប្រដាប់ចង្អុរស្លៃ ម៉េក្រូ វីដេអូ (សម្រាប់ថត) ម៉ាស៊ីនព្រីន ម៉ាស៊ីនស្កេន ។ |
| តើក្រុមការងារគម្រោងបំពេញតួនាទីអ្វីខ្លះ ? ហើយនរណាខ្លះនឹងបំពេញតួនាទីទាំងនោះ? | អ្នកគ្រប់គ្រងគម្រោង និង ក្រុមរៀបចំការអនុវត្តន៍វគ្គបណ្តុះបណ្តាលនឹងត្រូវបានបង្កើត ។ គេនឹងចែកជា៣ក្រុមតូចៗៈ (១) គ្រូឧទ្ទេស/អ្នកសម្របសម្រួល (២) សិក្ខាកាម (៣) ឯកសារ មធ្យោបាយ និងសម្ភារៈ (សូមមើលឯកសារមេរៀនស្តីពី ការរៀបចំវគ្គ) |
| តើត្រូវការអ្នកជំនាញការប្រភេទណាខ្លះ? | យោងតាមមេរៀនរបស់វគ្គ យើងជ្រើសរើសអ្នកជំនាញការដែលមានបទពិសោធន៍ច្រើន (ឧ. មន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុកការិយាល័យច្រកចេញចូលតែមួយ) |

### ៧. រយៈពេលវគ្គ

រយៈពេលសំដៅលើរយៈពេលដែលគេកំណត់សម្រាប់ធ្វើបទឧទ្ទេសនាម ។ រយៈពេលវគ្គអាចជះឥទ្ធិពលដល់ការសម្រេចចិត្តទាក់ទងនឹងការចំណាយ និងធនធាន ព្រមទាំងការរចនា និងការសម្រេចចិត្តក្នុងការបង្កើតខ្លឹមសារ ។ វាក៏អាចបញ្ជាក់ពីតម្រូវការសម្រាប់ការចំណាយលើការតាមដាននៅពេលវាយតម្លៃវគ្គបណ្តុះបណ្តាលផងដែរ ។

## ៨. ផែនការថវិកាសម្រាប់វគ្គ

### (1) ថវិកា

ថវិការួមមានការចំណាយដែលគេគិតទុកជាមុនដូចជាការចំណាយទៅលើអ្នកជំនាញការ ការធ្វើដំណើរមកចូលរួមវគ្គ ឧបករណ៍/សម្ភារៈដែលទិញឬជួល ការជួលមធ្យោបាយផ្សេងៗ ការបោះពុម្ភ ឯកសារបណ្តុះបណ្តាល (អត្ថបទ ឯកសារបង្ហាញ និងឯកសារយោងផ្សេងទៀត) និងសម្ភារៈសម្រាប់បណ្តុះបណ្តាល (ក្រដាស ប៊ិច និងប្រដាប់ដាក់ឯកសារមេរៀន) ។

សូមគិតថាតើយើងត្រូវជួលគេពីខាងក្រៅស្ថាប័នយើងអោយធ្វើអ្វីខ្លះ ។ ការជួលគេពីខាងក្រៅគួរពិចារណាផងដែរថា ពេលយើងធ្វើការងារនោះដោយខ្លួនឯងយើងចំណាយអស់ប៉ុន្មានរួមមានទាំងការរៀន សម្ភារៈ និងសុសវែរ (Software) ថ្លៃជាងតម្លៃដែលបុគ្គលិកយើងបានប៉ាន់ស្មានប៉ុណ្ណា ។

### (2) ឧបករណ៍ និងគំរូសម្រាប់ប្រើ

ផែនការបណ្តុះបណ្តាលជារបាយការណ៍មួយ ។ យើងអាចបង្កើតផែនការនេះដោយប្រើប្រាស់ឧបករណ៍ដូចជា អ្នកគ្រប់គ្រងគម្រោង កម្មវិធីកុំព្យូទ័រដូចជាអ៊ិចសែល(Excel) ដើម្បីបង្កើតពេលវេលា និងការបែងចែករចនាសម្ព័ន្ធការងារ(WBS)[1] (សូមយោងឯកសារស្តីពីការរៀបចំការបណ្តុះបណ្តាល) ។

**Figure 3: ឧទាហរណ៍នៃការបែងចែករចនាសម្ព័ន្ធការងារ**

[1] វិធីសាស្ត្រជាមូលដ្ឋានក្នុងការគ្រប់គ្រងវគ្គបណ្តុះបណ្តាលមួយដើម្បីកំណត់ និងរៀបចំទិដ្ឋភាពរួមនៃគម្រោងដោយគិតពីឋានានុក្រមនៃរចនាសម្ព័ន្ធដូចជាឋានានុក្រមនៃរចនាសម្ព័ន្ធដើមឈើ ។ កម្រិត២ដំបូងនៃ WBS (កម្រិតដំបូង និងកម្រិតទី២) កំណត់នូវលទ្ធផលដែលជាតំណាងឱ្យ ១00% នៃទំហំគម្រោង ។ នៅដំណាក់កាលបន្តបន្ទាប់គឺដូចជាកូនតំណាងឱ្យ១00% នៃទំហំរបស់មេ ។

# 5 ដំណាក់កាលទី៣ៈ បង្កើតវគ្គបណ្តុះបណ្តាល

ដំណាក់កាលទី៣នៃការធ្វើផែនការបណ្តុះបណ្តាលគឺត្រូវបង្កើតវគ្គបណ្តុះបណ្តាលរួមមានកម្មវិធីសិក្សា សេចក្តីសង្ខេបនៃមុខវិជ្ជា និងកំណត់ពីវិធីសាស្ត្របណ្តុះបណ្តាល និងប្រព័ន្ធផ្សព្វផ្សាយ និងឯកសារសម្រាប់បណ្តុះបណ្តាល ។






ការរចនាវគ្គគឺជាប្លង់នៃវគ្គបណ្តុះបណ្តាល និងជាព័ត៌មានលម្អិតអំពីវគ្គ ។ វារួមមានគោលបំណងវគ្គ ទិដ្ឋភាពទូទៅរបស់សិក្ខាកាម បញ្ជីកិច្ចការមុនវគ្គ គោលបំណងនានា ប្រធានបទ ខ្លឹមសារ មាតិកា វិធីសាស្ត្របណ្តុះបណ្តាល សម្ភារៈ/ឧបករណ៍ឧទ្ទេស ការពិពណ៌នាពីសកម្មភាពវគ្គ ការពិពណ៌នាពីវិធីសាស្ត្រវាយតម្លៃ តារាងពេលវេលាសម្រាប់វគ្គដែលបង្ហាញពីខ្លឹមសារជាបន្តបន្ទាប់ជាមួយពេលវេលា សម្ភារៈ/ឧបករណ៍ និងធនធានដែលត្រូវការ ។

គោលបំណងនៃការរចនាវគ្គគឺដើម្បីរៀបរាប់លម្អិតពីការរចនាវគ្គ និងផ្តល់ឱកាសក្នុងការកែតម្រូវលើកំហុសនានាដោយយោងទៅលើគោលបំណង និងខ្លឹមសារ ។ ការផ្តោតសំខាន់គឺទៅលើរចនាសម្ព័ន្ធ និងខ្លឹមសារវគ្គ ។ ប្លង់នៃការរចនាវគ្គត្រូវបានបង្ហាញជូននៅក្នុងគំនូសតាងខាងក្រោម។ មានឧទាហរណ៍ចំនួន២ទាក់ទងនឹងការរចនាវគ្គ ។ ឧទាហរណ៍ទី២គឺសាមញ្ញ ។ គេអាចសម្រេចចិត្តជ្រើសរើសយកប្រភេទឧទាហរណ៍ណាមួយអាស្រ័យលើពេលវេលា និងប្រភេទនៃវគ្គ ។ ផ្អែកតាមឧទាហរណ៍ខាងក្រោមនេះ យើងអាចរៀបចំប្លង់របស់យើងដោយខ្លួនឯងតាមការចាំបាច់ ។

## គំនូសតាងទី៤: គំរូទាក់ទងនឹងការរចនាវគ្គ

គំរូ
ទាក់ទងនឹង
ការរចនាវគ្គ

### ១. សេចក្តីណែនាំ

- **ឈ្មោះវគ្គបណ្តុះបណ្តាល**
  ផ្នែកនេះប្រាប់នូវចំណេះដឹងមុខវិជ្ជានៃវគ្គ អក្សរកាត់ (បើមាន) ការចេញផ្សាយ ជំនាន់ ឬការកែប្រែចំនួនវគ្គ
- **ទំហំវគ្គ**
  ផ្នែកនេះរៀបរាប់អំពីព្រំដែននៃវគ្គ
- **សម្ភារៈបណ្តុះបណ្តាល**
  ផ្នែកនេះសំដៅលើសម្ភារៈបណ្តុះបណ្តាលរួមមានសម្ភារៈដែលបានបោះពុម្ព និង សម្ភារៈជាអេឡិចត្រូនិច ។
- **រយៈពេលវគ្គ**
  ផ្នែកនេះប៉ាន់ប្រមាណពីពេលវេលាដែលសិក្ខាកាមត្រូវចំណាយពេញមួយវគ្គ ។ ត្រូវត្រៀមរយៈពេលប៉ាន់ប្រមាណនេះជាមួយនឹងរយៈពេលដែលគេប្រើសម្រាប់បង្កើតសម្ភារៈបណ្តុះបណ្តាល ។
- **ចំនួនសិក្ខាកាម**
  ផ្នែកនេះរៀបរាប់អំពីចំណុចកណ្តាល ចំណុចអតិបរមា ចំណុចអប្បបរមានៃថ្នាក់រៀន
- **កិច្ចការមុនវគ្គ**
  វគ្គនេះរៀបរាប់អំពីកិច្ចការនានា វិញ្ញាបនប័ត្រ ការធ្វើតេស្ត ឬសកម្មភាពនានាដែលអ្នករៀនត្រូវធ្វើមុនវគ្គ
- **អ្នកចូលរួម**
  ផ្តល់ព័ត៌មានដូចជា: មុខងារ ការទទួលខុសត្រូវ ទំហំនៃការងារជាមួយក្រសួងមហាផ្ទៃ ជីវប្រវត្តិ បទពិសោធពីមុន និងបទពិសោធដែលទាក់ទងសមត្ថភាពដែលមាន កម្រិតវប្បធម៌ អាកប្បកិរិយា របៀបរៀន ចំណង់ចំណូលចិត្ត បានធ្វើកិច្ចការមុនវគ្គ និងការរំពឹងទុក ។ វាអាចមានព័ត៌មានបន្ថែមទៀតដែលផ្តល់នូវភាពច្បាស់លាស់នៃការរៀនសូត្រដែលនាំទៅដល់ភាពជោគជ័យ ក្នុងការសម្រេចបាននូវគោលដៅវគ្គ ។
- **គោលបំណងនានានៃវគ្គ**
  ផ្នែកនេះរួមមានគោលបំណងនានា និងមានរៀបរាប់ពីគោលបំណងនានាថាតើវាស៊ីគ្នាទៅនឹងកម្មវិធីសិក្សាដែរឬទេ និងថាតើវគ្គបណ្តុះបណ្តាលនេះផ្តល់អត្ថប្រយោជន៍ដល់សិក្ខាកាមដោយរបៀបម៉េច? ផ្នែកនេះរួមមានការដោះស្រាយបញ្ហានានា និងកិច្ចការនានាដែលបង្ហាញពីភាពជោគជ័យដែលសម្រេចបាន ។
- **ការប៉ាន់ប្រមាណ និងការវាយតម្លៃវគ្គ**
  វាជាទិដ្ឋភាពទូទៅនៃវិធីសាស្ត្រដែលត្រូវបានគេប្រើប្រាស់ដើម្បីកំណត់ពីប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាល ។ ការវាយតម្លៃនេះមានសមាសធាតុ២: ព័ត៌មានត្រលប់ពីសិក្ខាកាមទាក់ទងនឹងភស្តុភារនៃវគ្គ និងកម្រិតនៃការទទួលចំណេះដឹង ព្រមទាំងការធ្វើតេស្តសិក្ខាកាមដើម្បីកំណត់ពីកម្រិតចំណេះដឹង ។

**តំនួសតាងទី៥: តំរូទាក់ទងនឹងការរចនាវគ្គ**

គំរូ
ទាក់ទងនឹង
ការរចនាវគ្គ

## ២. ខ្លឹមសារ

- **ឯកសារ/សម្ភារៈសម្រាប់ណែនាំ**
  ផ្នែកនេះមានឯកសារ និងបែបបទនានាដែលត្រូវចែកជូនសិក្ខាកាម អ្នកណែនាំ និងរដ្ឋបាល ។ ឯកសារ និង បែបបទនេះរួមមានឯកសារដែលបានបោះពុម្ព និងឯកសារជាអេឡិចត្រូនិច និងមធ្យោបាយនៃការទទួលឯកសារដូចជាការផ្ញើរតាមសារអេឡិចត្រូនិច និងការផ្ញើរតាមបណ្តាញ ។
- **រចនាសម្ព័ន្ធនៃឯកសារ**
  ផ្នែកនេះរៀបរាប់អំពីផ្នែកនៃវគ្គនីមួយៗដូចជាម៉ូឌុល មេរៀន និងលំហាត់ ។ ការរៀបរាប់នេះរួមមាន ខ្លឹមសាររយៈពេល ភាពជាប់ទាក់ទងគ្នានៃផ្នែកនីមួយៗ និងគោលបំណង ។
- **គោលបំណង និងការបំពេញកិច្ចការនានា**
  ផ្នែកនេះរួមមានគោលបំណងវគ្គ និងគោលបំណងនៃការបំពេញកិច្ចការនានា
- **លំដាប់លំដោយ និងសកម្មភាពវគ្គ**
  ផ្នែកនេះមានលំដាប់លំដោយនៃប្រធានបទវគ្គ និងរៀបរាប់សង្ខេបពីប្រធានបទនីមួយៗ ។ ប្រសិនបើរចនាបទនៃប្រធានបទនីមួយៗមានសង្គតិភាពនឹងគ្នា គេគួរតែរៀបរាប់វា ។
- **ខ្លឹមសារ**
  ផ្នែកនេះគឺជាការរៀបរាប់នូវខ្លឹមសារនៃម៉ូឌុល មេរៀន និងលំហាត់ ។ ការរៀបរាប់នេះគឺរៀបរាប់ពីអ្វីដែលមាន ជាជាងការរៀបរាប់ពីរបៀបចាត់ចែងអ្វីដែលមាន ។ ប្រសិនបើវាជាវគ្គផលិត គួរតែមានបញ្ជីនៃការផលិតនោះ ។
- **ពេលវេលាសម្រាប់ឧទ្ទេសនាម**
  ផ្នែកនេះរៀបរាប់អំពីពេលវេលាដែលគេបានរំពឹងទុកសម្រាប់ចំណាយទៅលើខ្លឹមសារនីមួយៗនៅពេលផ្តល់បទឧទ្ទេសនាម ។ វាអាចត្រូវបានបង្ហាញដោយខ្លី ហើយងាយស្រួលតាមរយៈតារាងពេលវេលា ។
- **តម្រូវការនានាទាក់ទងនឹងការបង្កើត**
  ផ្នែកនេះរួមមានធនធានដែលគេត្រូវការដើម្បីបង្កើតសម្ភារៈបណ្តុះបណ្តាល ។ សម្ភារៈនេះរួមមាន ហាតវែ (hard ware) សុសវែ (software)មេរៀន ឯកសារ បុគ្គលិក សេវាប្រឹក្សាយោបល់ ក្រុមការងារគម្រោង កន្លែងប្រជុំ ឧបករណ៍សម្រាប់ធ្វើតេស្ត កន្លែងទៅទស្សនា ឧបករណ៍សិប្បនិម្មិត ឧបករណ៍ផលិតខ្សែភាពយន្ត ធនធាន និងសម្ភារៈផ្សេងទៀតដែលត្រូវការសម្រាប់សម្របសម្រួល និងបញ្ចប់នូវដំណើរការបង្កើតវគ្គ។
- **តម្រូវការនៃការបញ្ជូន**
  ផ្នែកនេះរួមមានធនធានដែលត្រូវការដើម្បីបញ្ជូនផលិតកម្មនៃវគ្គ។ វាអាចរួមមានធាតុដូចគ្នាច្រើននៅក្នុង***តម្រូវការទាក់ទងនឹងការបង្កើត***។
- **តម្រូវការនៃការផលិត**
  ផ្នែនេះរួមមានធនធានដែលត្រូវការដើម្បីផលិតសម្ភារៈសម្រាប់បណ្តុះបណ្តាលដូចជា : អ្នកគ្រប់គ្រងបណ្តាញ អ្នករចនាប្រព័ន្ធផ្សព្វផ្សាយ សេវាកម្មចម្លងខ្សែភាពយន្ត ម៉ាស៊ីនព្រីន និងធនធានផ្សេងៗទៀតដែលអាចបញ្ជូនបាន។

## គំនូសតាងទី៦ៈ ឧទាហរណ៍ទាក់ទងនឹងការបង្កើតវគ្គដោយសាមញ្ញ

ឧទាហរណ៍ ទាក់ទងនឹង ការបង្កើតវគ្គ ដោយសាមញ្ញ

**ចំណងជើងៈ** ចំណងជើងគួរតែច្បាស់ និងរៀបរាប់ពីកម្មវិធីបណ្តុះបណ្តាល

**ទីកន្លែងៈ** ការជ្រើសរើសទីកន្លែងសម្រាប់បណ្តុះបណ្តាលគួរតែពិចារណាអំពីសកម្មភាពនៃការរៀន បរិវេណនៅក្នុងបន្ទប់រៀន ឧបករណ៍/សម្ភារៈ និងតម្លៃ ។ល។

**រយៈពេលៈ** ពេលវេលាដែលត្រូវចំណាយទៅលើគ្រប់ប្រធានបទដែលចាំបាច់ទាំងអស់

**ភ្នាក់ងារអនុវត្តៈ** ស្ថាប័នដែលទទួលបន្ទុករៀបចំវគ្គបណ្តុះបណ្តាល

**សិក្ខាកាមៈ**

ជាអ្នកដែលគេកំណត់ថាជានឹងចូលរួមវគ្គបណ្តុះបណ្តាល ។ គេគួរបញ្ជាក់ពីចំនួន និងប្រភេទ ( មុខរបរ ។ល ។) របស់សិក្ខាកាម

**១-សនិទានភាព**

វាធានានូវសកម្មភាពព្រមទាំងលទ្ធផលរំពឹងទុកនៃកម្មវិធីនានាដោយផ្អែកលើលទ្ធផលនៃការប៉ាន់ប្រមាណពីតម្រូវការបណ្តុះបណ្តាល ។

**២-គោលបំណងនានា**

វានិយាយអំពីការរំពឹងទុករបស់សិក្ខាកាមបន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាល ។

**៣-វិធីសាស្ត្រ**

ពិពណ៌នាអំពីយុទ្ធសាស្ត្រដែលត្រូវប្រើប្រាស់នៅពេលធ្វើការបណ្តុះបណ្តាលជាក់ស្តែង ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានវិធីសាស្ត្រណាមួយដែលល្អជាងគេបំផុតនោះទេ វាអាស្រ័យទៅលើការខិតខំប្រឹងប្រែងរបស់សិក្ខាកាមខ្លួនឯងប៉ុណ្ណោះ ។ ការគួបផ្សំគ្នានៃវិធីសាស្ត្រនានា ត្រូវបានគេរំពឹងថានឹងនាំមកនូវលទ្ធផលល្អ ។

**៤-ខ្លឹមសារវគ្គ**

ប្រធានបទដែលសំខាន់ជាងគេបំផុតគួរត្រូវបានរាយឈ្មោះដោយផ្អែកលើគោលបំណងនៃការបណ្តុះបណ្តាល ការពិចារណាពីពេលវេលា មធ្យោបាយដែលមាន ធនធាន និងហត្ថពលិក ។ បំបែកប្រធានបទចម្បងជាធាតុតូចៗជាក់លាក់ ។ ប្រធានបទដែលទាក់ទងគ្នាគួរត្រូវបានគេដាក់ជាក្រុមជាមួយគ្នាដើម្បីបន្តការគិត ។

**៥-លទ្ធផលរំពឹងទុក**

លទ្ធផលរំពឹងទុកជាញឹកញាប់ជាលទ្ធផលជាក់ស្តែងដែលទទួលបានភ្លាមៗបន្ទាប់ពីកម្មវិធីបណ្តុះបណ្តាល

**៦-ឧបករណ៍វាយតម្លៃ**

ឧបករណ៍វាយតម្លៃគួរត្រូវបានគេចែងច្បាស់ ។

**៧-តម្រូវការថវិកា**

ការប៉ាន់ប្រមាណនៃការចំណាយលើការបណ្តុះបណ្តាលទាំងមូលគួរត្រូវបានបញ្ចូល ។ ការចំណាយលើការ បង្កើតវគ្គ ការអនុវត្ត និងការវាយតម្លៃ គួរត្រូវបានរៀបចំ និងត្រូវបានធានា ។

**៨-គ្រឿងផ្គត់ផ្គង់ និងសម្ភារៈ**

គ្រឿងផ្គត់ផ្គង់ និងសម្ភារៈដែលត្រូវការសម្រាប់ពេលបណ្តុះបណ្តាលគួរត្រូវបានប្រាប់ពីគុណភាព និងតម្លៃ ។

**៩-ការគ្រប់គ្រងវគ្គ**

ការគ្រប់គ្រងវគ្គបណ្តុះបណ្តាលត្រូវមាន មន្ត្រីគម្រោង អ្នកសម្របសម្រួល ជំនួយការ ។ល។
ផ្នែកនេះគួររៀបរាប់ពីរចនាសម្ព័ន្ធក្នុងការគ្រប់គ្រង ការទទួលខុសត្រូវរបស់បុគ្គលិក ។

**១០-ការវាយតម្លៃវគ្គ**

វិធីសាស្ត្រក្នុងការវាយតម្លៃវគ្គគួរត្រូវបានគេនិយាយនៅទីនេះ ។
ព័ត៌មានលម្អិតទាក់ទងនឹងការវាយតម្លៃត្រូវបានពណ៌នា នៅក្នុង***ឯកសារមេរៀនស្តីពីការវាយតម្លៃវគ្គ*** ។

ឧទាហរណ៍ទាក់ទងនឹងវគ្គបណ្តុះបណ្តាលដែលបានព្រាងដោយPILAC ត្រូវបានរៀបរាប់ខាងក្រោម

**គំនូសតាងទី៧: គំរូទាក់ទងនឹងការបង្កើតវគ្គ**

PILAC

| | |
|---|---|
| **ចំណងជើង** | សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ |
| **ទីកន្លែង** | មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន |
| **រយៈពេល** | ៩-១០ កក្កដា ២០០៧: ១២៥រូប និង ១២-១៣ កក្កដា ២០០៧: ១២៥រូប |
| **អ្នកអនុវត្ត** | ក្រសួងមហាផ្ទៃ/ចៃកា |
| **សិក្ខាកាម** | អភិបាល អភិបាលរងខេត្ត មន្ត្រីជាន់ខ្ពស់មកពីក្រសួងនានា (១២៥រូប x ២ = ២៥០រូប) |
| **សនិទានភាព** | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅឆ្នាំ២០០៥ដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ទោះបីជាយ៉ាងណាក៏ដោយការប៉ាន់ប្រមាណពីតម្រូវការបណ្តុះបណ្តាលបានរកឃើញថា មន្ត្រីមិនយល់ដឹងច្រើនអំពីវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន ។ |
| **គោលបំណងនានា** | (អភិបាល អភិបាលរងទាំងអស់) យល់ពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋានដើម្បីជំរុញដល់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការប្រព្រឹត្តទៅដោយរលូន |
| **វិធីសាស្ត្រ** | ឧទ្ទេសនាម ក្រុមពិភាក្សា សំណួរ និងចម្លើយ |
| **ខ្លឹមសារវគ្គ** | ❑ ការវិវត្តន៍នៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ច្បាប់រៀបចំអង្គការស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>❑ រដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន<br>❑ ករណីសិក្សាអំពីការផ្តល់សេវាក្នុងវិស័យសាធារណៈ |
| **គ្រូឧទ្ទេស** | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ អ្នកជំនាញការជប៉ុន និងអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍនៅកម្ពុជា |
| **លទ្ធផលរំពឹងទុក** | សិក្ខាកាមទាំងអស់អាចយល់ពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន |
| **តម្រូវការថវិកា** | xx ដុល្លារអាមេរិច |
| **គ្រឿងផ្គត់ផ្គង់ និងសម្ភារៈ** | ឯកសារយោង ស្លៃបង្ហាញ ប្រកាសដែលទាក់ទង ក្រដាសនិងប៊ិចសម្រាប់ក្រុមពិភាក្សា ម៉ាស៊ីនបញ្ចាំងពន្លឺ កំព្យូទ័រ ក្តារខៀន ។ល។ |
| **ការគ្រប់គ្រងវគ្គ** | ក្រុមការងារគម្រោងភីឡាក់ (ក្រុមការងារ អ.រ.ម និងអ្នកជំនាញការចៃកា) |
| **ការវាយតម្លៃវគ្គ** | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ (ខ្លឹមសារបណ្តុះបណ្តាល ឯកសារ/សម្ភារៈ កម្រិតនៃការយល់) ត្រូវបានវាយតម្លៃដោយសិក្ខាកាម |

ការបង្កើត
កម្មវិធីសិក្សា

***កម្មវិធីសិក្សា*** ជាការរៀបរាប់អំពីទិសដៅ និងគោលបំណងនានា ខ្លឹមសារ បទពិសោធន៍ លទ្ធផល និងដំណើរការនៃកម្មវិធីបណ្តុះបណ្តាលរួមមានៈ

- ❑ *ការរៀបរាប់អំពីរចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល (លក្ខខណ្ឌនៃការចូលរៀន រយៈពេល និងការរៀបចំកម្មវិធីបណ្តុះបណ្តាលរួមមានប្រព័ន្ធវាយតម្លៃ)*
- ❑ *ការរៀបរាប់ពីវិធីសាស្ត្រក្នុងការរៀន ការបង្រៀន និងការផ្តល់ព័ត៌មានត្រលប់*

កម្មវិធីសិក្សាអាចគ្របដណ្តប់ទាំងជំនាញ និងបច្ចេកទេសជាក់លាក់ ។ ខ្លឹមសារនៃកម្មវិធីសិក្សាគួរត្រូវបាននិយាយអំពីចំណេះដឹង ជំនាញ និងបទពិសោធដែលសិក្ខាកាមនឹងទទួលបាន ។

ការបង្កើត
កម្មវិធីសិក្សា

***ការបង្កើតកម្មវិធីសិក្សា*** ជាការបង្កើតឡើងវិញ ឬការកែសម្រួលអ្វីដែលបានបង្រៀនរួចហើយ រីឯការវាយតម្លៃកម្មវិធីសិក្សានាំផ្លូវក្នុងការធ្វើសេចក្តីសម្រេច បម្រើដល់តម្រូវការគណនេយ្យភាព និងជំរុញដល់ការយល់ដឹងពីកម្មវិធីសិក្សា ។ មគ្គុទេសក៏កម្មវិធីសិក្សារួមមានគោលដៅនៃការបង្រៀន និងយុទ្ធសាស្ត្រណែនាំ មុខវិជ្ជានៃការសិក្សា សេចក្តីសង្ខេបមុខវិជ្ជា ឬប្លង់នៃខ្លឹមសារ លទ្ធផលនៃការរៀន និងការចាត់ចែងពេលវេលា ។

## គំនូសតាងទី៨ៈ គំរូទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាល

| | |
|---|---|
| **ចំណងជើងវគ្គ** | វគ្គបណ្តុះបណ្តាលអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន |
| **គោលបំណងនានា** | មន្ត្រីក្រសួងមហាផ្ទៃអាចជំរុញវិមជ្ឈការ និងវិសហមជ្ឈការដោយរលូនតាមរយៈការយល់ពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន |
| **វគ្គបណ្តុះបណ្តាល** | ១. សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់<br>២. វគ្គបណ្តុះបណ្តាលមន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| **រយៈពេល** | ១. ៩-១០ កក្កដា ២០០៧ៈ ១២៥រូប និង កក្កដា ១២-១៣ ២០០៧ : ១២៥រូប<br>២. ១៩-២០(២៥រូប), ២៣-៣៤(២៥រូប), ២៦-២៧ (២៥រូប), ៣០-៣១ កក្កដា ២០០៧ (២៥រូប) |
| **ទីកន្លែង** | នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន |
| **សិក្ខាកាម** | ១. មន្ត្រីរដ្ឋបាលជាន់ខ្ពស់នៃ អ.រ.ម និងមន្ត្រីរាជការមកពីក្រសួងពាក់ព័ន្ធ (១២៥រូប X ២ដង = ២៥០រូប)<br>២. មន្ត្រី អ.រ.ម ទាំងអស់ (២៥រូប X ៤ដង = ១០០រូប) |
| **វិធីសាស្ត្រ** | ឧទ្ទេសនាម ក្រុមពិភាក្សា សំណួរនិងចម្លើយ |
| **គ្រូឧទ្ទេស/អ្នកសម្របសម្រួល** | ក្រុមការងារ អ.រ.ម មន្ត្រីក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធផ្សេងទៀត |
| **ខ្លឹមសារវគ្គ** | ❑ ការវិវត្តន៍នៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ច្បាប់រៀបចំអង្គការស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>❑ រដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន<br>❑ ករណីសិក្សាអំពីការផ្តល់សេវាក្នុងវិស័យសាធារណៈ<br>❑ ការពិភាក្សាក្រុម |
| **ភ្នាក់ងារអនុវត្ត** | ក្រសួងមហាផ្ទៃ គាំទ្រដោយចៃកា |
| **លទ្ធផលរំពឹងទុក** | សិក្ខាកាមទាំងអស់អាចយល់ពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន |
| **ការគ្រប់គ្រងវគ្គ** | ក្រុមការងារគម្រោងភីឡាក់ (ក្រុមការងារ អ.រ.ម និងអ្នកជំនាញការចៃកា) |
| **ការវាយតម្លៃវគ្គ** | ១-លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ (ខ្លឹមសារបណ្តុះបណ្តាល ឯកសារ/សម្ភារៈ កម្រិតនៃការយល់) ត្រូវបានវាយតម្លៃដោយសិក្ខាកាម<br>២-ការធ្វើតេស្តមុន និងក្រោយវគ្គ-លក្ខណៈវិនិច្ឆ័យ (គ្រូឧទ្ទេស/អ្នកសម្របសម្រួល ខ្លឹមសារបណ្តុះបណ្តាល ឯកសារ/សម្ភារៈ កម្រិតនៃការយល់ដឹង) ត្រូវបានវាយតម្លៃដោយសិក្ខាកាម |

ការរៀបចំ
ការសង្ខេបមុខវិជ្ជា
(Syllabus formulation)

***ការសង្ខេបមុខវិជ្ជា***(Syllabus) បង្ហាញពីសមាសធាតុនៃវគ្គបណ្តុះបណ្តាលតាមលំដាប់លំដោយ និងការចាត់ចែងពេលវេលាវាំងខ្លឹមសារខុសគ្នា ។ ទោះបីជាប្រធានបទមានលំដាប់លំដោយយ៉ាងណាក៏ដោយ ក៏សមត្ថភាពរបស់សិក្ខាកាមគួរត្រូវបានពិចារណា ហើយប្រធានបទគួរសមស្របដើម្បីសម្រេចនូវគោលបំណងនានានៃវគ្គ ។ មានលក្ខណៈវិនិច្ឆ័យជាទូទៅចំនួន០៣ដើម្បីពិចារណាក្នុងការរៀបចំសង្ខេបមុខវិជ្ជាៈ (១) គោលបំណង នានានៃវគ្គ (២) សិក្ខាកាម និង(៣)តម្រូវការក្នុងការអនុវត្ត ។ សំណួរគន្លឹះមានដូចខាងក្រោមៈ

- *តើអ្វីទៅជាគោលបំណងនៃម៉ូឌុលដែលបានកំណត់សម្រាប់សម្រេចបាននូវគោលបំណងនានានៃវគ្គបណ្តុះបណ្តាល ?*
- *តើគួរប្រើវិធីសាស្រ្តណាមួយដើម្បីអោយវគ្គមានប្រសិទ្ធិភាព?*
- *តើឧបករណ៍/សម្ភារៈឧទ្ទេសអ្វីដែលត្រូវការ?*
- *តើមានរយៈពេលប៉ុន្មានដើម្បីសម្រេចនូវគោលបំណង?*

PILAC

**តារាងទី៦ៈ គំរូសេចក្តីសង្ខេបមុខវិជ្ជា**

| ល.រ | ចំណងជើងម៉ូឌុល | គោលបំណងនានា | វិធីសាស្រ្ត | សម្ភារៈ | ពេលវេលា |
|---|---|---|---|---|---|
| ១ | គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា | យល់ពី គោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ | ឧទ្ទេសនាម ក្រុមពិភាក្សា | ឯកសារចែក | ១ ម៉ោង |
| ២ | ករណីសិក្សាៈ ច្រកចេញចូលតែមួយ | យល់ពីសកម្មភាពនៃការផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធិភាព | ឧទ្ទេសនាម ក្រុមពិភាក្សា រូបភាពឬភាពយន្ត | ឯកសារចែក កាបញ្ចាំង ខ្សែភាពយន្ត | ១ ម៉ោង ៣០នាទី |

PILAC

កម្មវិធីបណ្តុះបណ្តាលអំពីសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៅដំណាក់កាលទី១របស់គម្រោងភីឡាក់ត្រូវបានបង្ហាញជូនខាងក្រោម ។

## តារាងទី៧: កម្មវិធីបណ្តុះបណ្តាល (សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់)

| | | |
|---|---|---|
| **ថ្ងៃទី១: ០៩ កក្កដា ២០០៧** | | |
| 8:00-8:30 | ចុះឈ្មោះ | ក្រុមការងា អ.រ.ម |
| 8:30-9:00 | ពិធីបើកវគ្គ | H.E. Prum Sokha |
| 9:00-9:30 | វគ្គទី១: សេចក្តីផ្តើម<br>-សង្ខេបពីគម្រោងភីឡាក់<br>-ណែនាំពីកម្មវិធីថ្ងៃទី១ | Dr. Kato (JICA) |
| 9:30-10:00 | សម្រាកអាហារសម្រន់ | |
| 10:00-11:00 | វគ្គទី២: ការវិវត្តទៅនៃវិមជ្ឈការ និងវិសហមជ្ឈការ | H.E. Sak Setha |
| 11:00-12:00 | វគ្គទី៣: ច្បាប់រៀបចំអង្គការស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | H.E. Sak Setha |
| 12:00-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:00 | វគ្គទី៤: ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅជប៉ុន | Mr. Kamiko (JICA Expert) |
| 15:00-15:15 | សម្រាកអាហារសម្រន់ | |
| 15:15-16:15 | វគ្គទី៥: ហិរញ្ញវត្ថុសាធារណៈនៅជប៉ុន | Mr. Kamiko (JICA Expert) |
| 16:15-17:00 | វគ្គទី៦: លំហាត់ | ក្រុមការងា អ.រ.ម |
| **ថ្ងៃទី២: ១០ កក្កដា ២០០៧** | | |
| 7:45-8:00 | ចុះឈ្មោះ | ក្រុមការងា អ.រ.ម |
| 8:00-8:30 | វគ្គទី៧: រំលឹកថ្ងៃទី១<br>- រំលឹកថ្ងៃទី១ និងណែនាំពីកម្មវិធីថ្ងៃទី២ | ក្រុមការងា អ.រ.ម |
| 8:30-9:30 | វគ្គទី៨: ការឆ្លុះបញ្ចាំងពីលំហាត់ | H.E. Leng Vy |
| 9:30-10:00 | សម្រាកអាហារសម្រន់ | |
| 10:00-11:00 | វគ្គទី៩: ករណីសិក្សាៈ ការិយាល័យច្រកចេញចូលតែមួយ | Asia Urbs |
| 11:00-12:00 | វគ្គទី១០: គណនេយ្យភាព និងសេវាសាធារណៈនៃការធ្វើវិមជ្ឈការនៅកម្ពុជា | Cambodia Development Resource Institute |

| | | |
|---|---|---|
| 12:00-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:00 | វគ្គទី១១: សំណួរ និងចម្លើយ | Dr. Kato (JICA Expert) |
| 15:00-15:30 | វគ្គទី១២: បញ្ជីសំណួរសម្រាប់វាយតម្លៃ<br>-ការចែក និងការប្រមូលបញ្ជីសំណួរថ្ងៃទី១ ថ្ងៃទី២ និងជារួម | ក្រុមការងា អ.វ.ម |
| 15:30-15:45 | វគ្គទី១៣: ធ្វើរបាយការណ៍សិក្ខាសាលា | ក្រុមការងា អ.វ.ម |
| 15:45-16:15 | វគ្គទី១៤: ពិធីបិទវគ្គ | H.E. Prum Sokha |
| 16:15-16:45 | វគ្គទី១៥: ចែកវិញ្ញាបនប័ត្រ | H.E. Prum Sokha |

PILAC

កម្មវិធីបណ្តុះបណ្តាលមន្ត្រី អ.វ.ម នៅដំណាក់កាលទី១ របស់គម្រោងភីឡាក់មានដូចខាងក្រោម

**តារាងទី៨: កម្មវិធីបណ្តុះបណ្តាល (មន្ត្រី អ.វ.ម)**

| ថ្ងៃទី១: ១៩, ២៣, ២៦, ៣០, ខែកក្កដា ២០០៧ | | |
|---|---|---|
| 8:00-9:00 | វគ្គទី១: សេចក្តីផ្តើម និងការធ្វើតេស្តមុនវគ្គ<br>-សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាល<br>-តេស្តមុនវគ្គ | ក្រុមការងារ អ.វ.ម |
| 9:00-9:30 | វគ្គទី២: សង្ខេបពីគម្រោងភីឡាក់ | Dr. Kato (JICA Expert) |
| 9:30-10:15 | វគ្គទី៣: ប្រព័ន្ធរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន (១) | ក្រុមការងារ អ.វ.ម |
| 10:15-10:30 | សម្រាកអាហារសម្រន់ | |
| 10:30-11:15 | វគ្គទី៤: ប្រព័ន្ធរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន (២) | ក្រុមការងារ អ.វ.ម |
| 11:15-12:15 | វគ្គទី៥: ទ្រឹស្តីនៃវិមជ្ឈការ និងវិសហមជ្ឈការ និងការអនុវត្តន៍ | ក្រុមការងារ អ.វ.ម |
| 12:15-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:00 | វគ្គទី៥: ច្បាប់រៀបចំអង្គការស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ក្រុមការងារ អ.វ.ម |
| 15:00-16:30 | វគ្គទី៦: ការងារជាក្រុមៈ លំហាត់ពីរបៀបពន្យល់ពីវិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជាសម្រាប់មន្ត្រីថ្នាក់ខេត្ត | ក្រុមការងារ អ.វ.ម |
| 16:30-17:00 | វគ្គទី៧: សំណួ និងចម្លើយ | ក្រុមការងារ អ.វ.ម |

| | | |
|---|---|---|
| | -សំណួរ និងចម្លើយ<br>-ប្រមូលបញ្ជីសំណួរថ្ងៃទី១ | |
| **ថ្ងៃទី២: ២០, ២៤, ២៧, ៣១, ខែកក្កដា ២០០៧** | | |
| 8:00-8:30 | វគ្គទី៨: រំលឹកថ្ងៃទី១<br>-រំលឹកថ្ងៃទី១ និងណែនាំកម្មវិធីថ្ងៃទី២ | ក្រុមការងារ អ.រ.ម |
| 8:30-9:30 | វគ្គទី៩: ករណីសិក្សា: ការិយាល័យច្រកចេញចូលតែមួយ | Asia Urbs |
| 9:30-10:30 | វគ្គទី១០: ការងារក្រុម: ការិយាល័យច្រកចេញចូលតែមួយ | ក្រុមការងារ អ.រ.ម |
| 10:30-11:00 | សម្រាកអាហារសម្រន់ | |
| 11:00-12:00 | វគ្គទី១០: ការងារក្រុម: ការិយាល័យច្រកចេញចូលតែមួយ | ក្រុមការងារ អ.រ.ម |
| 12:00-14:00 | សម្រាកអាហារសម្រន់ | |
| 14:00-15:00 | វគ្គទី១១: រំលឹក និងការឆ្លុះបញ្ចាំងវគ្គ | ក្រុមការងារ អ.រ.ម |
| 15:00-15:45 | វគ្គទី១២: ធ្វើតេស្តក្រោយវគ្គ និងបញ្ជីសំណួរ<br>-ចែក និងប្រមូលបញ្ជីសំណួរថ្ងៃទី២ និងជារួម<br>-ធ្វើតេស្តក្រោយវគ្គ | ក្រុមការងារ អ.រ.ម |
| 15:45-16:00 | វគ្គទី១៣: ចែកវិញ្ញាបនប័ត្រ | អគ្គនាយក |
| 16:00-16:30 | វគ្គទី១៤: បិទវគ្គ | អគ្គនាយក |

**វិធីសាស្ត្រ បណ្តុះបណ្តាល និង សម្ភារៈ/ឧបករណ៍ ឧទ្ទេស**

ផ្អែកតាមការវិភាគរបស់អ្នក អ្នកបានដឹងហើយថាសិក្ខាកាមជានរណា ពួកគេចេះអ្វី ហើយពួកគេត្រូវការចេះអ្វីទៀត ។ អ្នកបានកំណត់គោលដៅវគ្គ គោលបំណងនានានៃការរៀន និងរបៀបដែលគេធ្វើតេស្តទៅលើគោលដៅ និងគោលបំណងនេះ ។ អ្នកមានផែនទីណែនាំដែលនៅក្នុងនោះមានលំដាប់លំដោយនៃប្រធានបទនានា និងរយៈពេលនៃប្រធានបទនីមួយៗដែលសិក្ខាកាមត្រូវចំណាយ ។ ផែនទីណែនាំនោះក៏រួមមានសំណើនៃវិធីសាស្ត្របណ្តុះបណ្តាល និងសម្ភារៈ /ឧបករណ៍ឧទ្ទេសដែលហាក់ដូចជាសាកសមបំផុត ។

វិធីសាស្ត្របណ្តុះបណ្តាលជាយុទ្ធសាស្ត្រសម្រាប់ផ្តល់បទឧទ្ទេសនាមពីខ្លឹមសារមេរៀន ។ វាចំណាយពេលវេលាដើម្បីសម្រេចចិត្តពីរបៀបចាត់ចែងវិធីសាស្ត្របណ្តុះបណ្តាលនានា ដែលវិធីសាស្ត្របណ្តុះបណ្តាលនេះអាចត្រូវបានគេពិពណ៌នាតាមចរិកលក្ខណៈច្រើន ។ ដោយសារពេលវេលា តម្លៃ និងការ

ខិតខំប្រឹងប្រែងជាកត្តាចំបងចំពោះគម្រោងបណ្តុះបណ្តាលភាគច្រើន ដូចនេះតារាងប្រៀបធៀបដែលមាននៅខាងក្រោមនេះត្រូវបានគេចាត់ថ្នាក់តាមពេលវេលា តម្លៃ និងការខិតខំប្រឹងប្រែង (ភាពស្មុគស្មាញ) ។ កត្តាសំខាន់ៗផ្សេងៗទៀតក្នុងការជ្រើសរើសយកវិធីសាស្ត្របណ្តុះបណ្តាលណាមួយនោះគឺ អ្នកជំនាញក្នុងការបណ្តុះបណ្តាល កម្រិតនៃការប្រតិកម្មរបស់អ្នករៀន និង សក្តានុពលដែលអាចនាំអោយមានកម្រិតនៃការរៀនបានខ្ពស់ ។

ចរិកលក្ខណៈនៃវិធីសាស្ត្របណ្តុះបណ្តាល

### តារាងទី៩: ចរិកលក្ខណៈនៃវិធីសាស្ត្របណ្តុះបណ្តាល

| | បទឧទ្ទេសនាម | សំណួរ | លំហាត់ | ការពិភាក្សា | ការពិភាក្សាក្រុមតូច | ការសម្របសម្រួល | វាគ្មិន | ក្រុមអ្នកជំនាញការ | ការបំផុតគំនិត | ករណីសិក្សា | សំដែងតួ | បទពិសោធន៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពេលវេលា | L | M | M | M | M | M | L | L | L | M | M | M |
| តម្លៃ | L | L | L | L | L | L | L,M | L | L | L | L | M,H |
| ការខំប្រឹងប្រែង | L | L | L | L | L | M | L | L | L | L,M | L,M | M |
| កម្រិត នៃការ | L | M | M,H | M,H | M,H | H | L | L,M | H | H | H | H |

កំណត់សំគាល់: ខ្ពស់ (H), ល្មម (M) , ទាប (L) នៃពេលវេលា តម្លៃ ឬការខំប្រឹងប្រែង

(ប្រភព: Hassell-Corbiell (2001). *Developing Training Courses*)

## តារាងទី១០: វិធីសាស្រ្តបណ្តុះបណ្តាល

វិធីសាស្រ្ត
បណ្តុះបណ្តាល

| វិធីសាស្រ្ត | ខ្លឹមសារ |
|---|---|
| បទឧទ្ទេសនាម | ❑ នៅក្នុងវិធីសាស្រ្តបង្រៀនតាមបែបបុរាណៈ គ្រូនិយាយ ហើយសិក្ខាកាមស្តាប់ ។ គ្រូអាចអនុញ្ញាតថាតើអោយសិក្ខាកាមសួរឬក៏អត់ ។ វិធីសាស្រ្តក្នុងការផ្តល់បទឧទ្ទេសនាម គឺផ្តល់ឱកាសតិចតួច ឬមិនផ្តល់ឱកាសអោយសិក្ខាកាមសួរតែម្តង ។<br>❑ វិធីសាស្រ្តបែបនេះអាចត្រូវបានគេប្រើប្រាស់សម្រាប់បទបង្ហាញខ្លីៗពីមួយម៉ោង ទៅពីរម៉ោង ការផ្តល់ព័ត៌មាន និងបញ្ចេញព័ត៌មានឱ្យបានច្រើន (ដែលត្រូវបានគេរំពឹងថា សិក្ខាកាមនឹងមិនចងចាំ ឬយល់ តែត្រូវតែដឹង) នៅក្នុងរយៈពេលខ្លីមួយ ។ វិធីសាស្រ្តនេះក៏សមស្របផងដែរចំពោះសិក្ខាកាមដែលមានជំនាញ និងចំណេះដឹងកម្រិតទាប នោះសមត្ថភាពនៃការប្រតិកម្មរបស់គាត់នៅមានកម្រិត ។<br>❑ ការផ្តល់បទឧទ្ទេសនាមនាំផ្លូវ អាចត្រូវបានគេរំពឹងថានាំមកនូវកម្រិតនៃការយល់ដឹងទាបជាងគេ ដូចជា ការយល់ដឹងជាមូលដ្ឋាន និងការរកនឹក ឬការនឹកឃើញ ។<br>❑ ដើម្បីសម្រេចបានកម្រិតនៃការយល់ដឹងក្នុងការរៀនសូត្របានកម្រិតខ្ពស់ជាងនេះ ខ្លឹមសារវគ្គអាចបញ្ចូលនូវការហ្វឹកហាត់ សំណួរនានាដែលតម្រូវឱ្យមានសកម្មភាពនៃការយល់ដឹងកម្រិតខ្ពស់ និងលំហាត់ដែលអាចឱ្យ អ្នករៀនមានការប្រតិកម្ម និង ការគិតកម្រិតខ្ពស់ ។ |
| សំណួរ | ❑ ការសួរសំណួរដល់សិក្ខាកាមជាវិធីសាស្រ្តបណ្តុះបណ្តាលមួយ ។ ការសួរនូវសំណួរបើកដូចជាសំណួរទាំងឡាយណាដែលចាប់ផ្តើមដោយ ***ជាមួយនរណា តើអ្វី នៅពេលណា នៅកន្លែងណា និងដោយរបៀបណា*** ឱ្យសិក្ខាកាមគិតជាជាងឱ្យគាត់ស្តាប់ ហើយឱ្យគាត់ប្រតិកម្មជាជាងឱ្យគាត់គិតទុកក្នុងចិត្តហើយព្យាយាមគិតឬស្វែងយល់ដោយខ្លួនឯង ។<br>❑ សំណួរគួរត្រូវបានគេរៀបចំរួចជាស្រេចនៅក្នុងសៀវភៅណែនាំរបស់គ្រូឧទ្ទេសដើម្បីឆ្លើយតបនូវសកម្មភាពនានារបស់សិក្ខាកាម ។ ការសួរនូវសំណួរថា ***ហេតុអ្វី*** ហាក់ដូចជាបង្ខំសិក្ខាកាមឆ្លើយការពារ ហើយហាក់ដូចជាអ្នកសួរកំពុងប្រកួតប្រជែងជាមួយសិក្ខាកាម ឬរករឿងសិក្ខាកាម ។ |
| លំហាត់ | ❑ ការហ្វឹកហាត់ ការធ្វើសំណួរ និងការលេងល្បែងជាបុគ្គល ឬជាក្រុមផ្តល់ឱកាសឱ្យសិក្ខាកាមបានបង្ហាញនូវកម្រិតនៃការយល់ដឹង និងត្រួតពិនិត្យនូវការយល់ដឹងរបស់សិក្ខាកាមផងដែរ ។ |
| ការពិភាក្សា | ❑ សកម្មភាពនៃការពិភាក្សាបង្ហាញពីប្រធានបទផ្សេងៗគ្នាដល់សិក្ខាកាម ។ បុគ្គល ឬក៏ក្រុមត្រូវបានគេចាត់តាំងឱ្យការពារនូវទស្សនៈផ្សេងៗគ្នា<br>❑ វិធីសាស្រ្តនេះអាចនាំឱ្យសិក្ខាកាមមានការអនុវត្តន៍ ការវិភាគ ការសំយោគ និងការវាយតម្លៃទៅលើកម្រិតនៃការយល់ដឹង ។ គុណវិបត្តិនោះគឺថា អ្នករៀនភាគច្រើនបានស្តាប់ ហើយមួយចំនួនតូចទទួលបានរង្វាន់ក្នុងការសម្របសម្រួល និងបញ្ចេញយោបល់ ។ |

| | |
|---|---|
| ការពិភាក្សាក្រុមតូច | ❑ វាមានចរិកលក្ខណៈ និងគុណសម្បត្តិដូចការពិភាក្សាក្រុមដែរ តែវាមានគុណសម្បត្តិមួយបន្ថែមទៀតគឺថា អ្នករៀនភាគច្រើនមានឱកាសក្នុងការចូលរួម ។<br>❑ វិធីសាស្រ្តបណ្តុះបណ្តាលនេះមាន២កម្រិតៈ កាពិភាក្សាក្រុមតូចជាកម្រិតមួយដែលអ្នករៀនភាគច្រើន ឬទាំងអស់មានឱកាសក្នុងការចូលរួម រីឯកម្រិតក្នុងការរាយការណ៍ជាកិច្ចការដែលអ្នកឡើងបង្ហាញបានបង្ហាញពីលទ្ធផលរកឃើញរបស់ក្រុមជូនដល់ថ្នាក់រៀនទាំងមូល |
| ការសម្របសម្រួល | ❑ ជាដំណើរការដែលដឹកនាំដោយគ្រូមួយរូប ហើយគ្រូនោះណែនាំពីដំណើរការមួយ ហើយបន្ទាប់មកធ្វើការបង្វឹកសិក្ខាកាមដោយសួរជាសំណួរ ណែនាំអំពីការហ្វឹកហាត់ ផ្តល់ឬបង្កើតជាឧទាហរណ៍ និងទម្រង់បែបបទការងារ<br>❑ ជាវិធីសាស្រ្តដែលដឹកនាំដោយគ្រូមួយរូប ដែលជាអន្តរកម្ម ហើយសិក្ខាមមានចំណេះដឹង និងជំនាញជាមូលដ្ឋាន តែមិនទាន់គ្រប់គ្រាន់ក្នុងការដឹកនាំដោយខ្លួនឯងបានទេ |
| វាគ្មិន | ❑ ការសរសេរសុន្ទរកថារបស់វាគ្មិនជាវិធីមួយដែលចំណាយលុយតិចក្នុងការប្រមូលនូវខ្លឹមសារវគ្គ ។ ដើម្បីឱ្យមានប្រសិទ្ធិភាព យើងត្រូវឱ្យវាគ្មិននូវប្រធានបទ គោលបំណងនានា ពេលវេលាសម្រាប់និយាយ និងសំណួរដែលគួរឆ្លើយ<br>❑ កម្រិតនៃការរៀនដែលប្រើប្រាស់វាគ្មិន វាមានលក្ខណៈផ្សេងគ្នាពីប្រសិទ្ធិភាពនៃបទឧទ្ទេសនាមមួយ ហើយអាចត្រូវបានគេវាយតម្លៃខ្ពស់ប្រសិនបើជំនាញរបស់វាគ្មិនទាក់ទាញអារម្មណ៏របស់អ្នករៀន |
| ក្រុមអ្នកជំនាញការ | ❑ ក្រុមអ្នកជំនាញការមានគុណសម្បត្តិដូចវាគ្មិនដែរ និងមានបន្ថែមភាពផ្សេងគ្នាផងដែរ ។ វិធីសាស្រ្តនេះសមស្របសម្រាប់ពិចារណាអំពីទស្សនៈផ្សេងៗគ្នា ឬក៏ផ្តល់នូវមូលដ្ឋានសម្រាប់ពិភាក្សា ឬករណីសិក្សា<br>❑ អ្នកគួររៀបចំបញ្ជីអ្នកជំនាញការជាមួយប្រធានបទ គោលបំណងនានានៃការរៀន ពេលវេលាសម្រាប់សកម្មភាព និងបញ្ជីបញ្ហាដែលត្រូវដោះស្រាយ ( ប្រសិនបើសមស្រប) |

(ប្រភពៈ Hassell-Corbiell (2001). *Developing Training Courses*)

## តារាងទី១១: វិធីសាស្ត្របណ្តុះបណ្តាល

វិធីសាស្ត្រ
បណ្តុះបណ្តាល

| វិធីសាស្ត្រ | ខ្លឹមសារ |
|---|---|
| ការបំផុសគំនិត | ❑ វិធីសាស្ត្រនេះមានប្រសិទ្ធិភាពនៅពេលដែលអ្នករៀនភ្ជាប់ខ្លួនទៅនឹងយុទ្ធសាស្ត្រផ្លាស់ប្តូរ និងឧបករណ៍នៃការដោះស្រាយបញ្ហាដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតបានជាគំនិត<br>❑ មានអ្នកសម្របសម្រួលដែលធ្វើបញ្ជីនៃគំនិតដែលបញ្ចេញដោយសិក្ខាកាម និងសួរសំណួរបិទដែលបង្កើតបានជាការវិភាគ ការសំយោគ និងការគិត |
| ករណីសិក្សា | ❑ ជាសកម្មភាពមួយដែលពណ៌នាពីស្ថានភាពពិតនៃជីវិត ឬក៏សក្តានុពលនៃស្ថានភាពនៃជីវិត ការចោទឡើងជាបញ្ហា សួរដើម្បីរកដំណោះស្រាយ ប្រៀបធៀបដំណោះស្រាយជាមួយនឹងស្ថានភាពពិតនៃជីវិត និងវាយតម្លៃគ្រប់ដំណោះស្រាយទាំងអស់<br>❑ ការសម្របសម្រួលដោយត្រឹមត្រូវជាវិធីសាស្ត្រមួយដែលពាក់ព័ន្ធនឹងកម្រិតខ្ពស់នៃការរៀន និងប្រសិទ្ធិភាពនៃការរៀន |
| ការសំដែងតួ | ❑ ការសំដែងតួតម្រូវឱ្យអ្នករៀនដើរតួនៅក្នុងស្ថានភាពមួយដែលទំនងជានឹងកើតឡើង ។ វាតម្រូវឱ្យមានការហ្វឹកហាត់ និងការផ្តល់ព័ត៌មានត្រលប់ភ្លាមៗដើម្បីគាំទ្រ<br>❑ ការសំដែងតួជាវិធីសាស្ត្រមួយសាកសមបំផុតសម្រាប់អនុវត្តនូវជំនាញដូចជា ការធ្វើបទបង្ហាញ ការធ្វើសម្ភាសន៍ ការវាយតម្លៃ និងការពិភាក្សា ហើយអាចធ្វើឱ្យការរៀនទទួលបានកម្រិតមួយជាទីពេញចិត្ត (ធ្វើឱ្យរំភើប និងរំជួលចិត្ត) |
| បទពិសោធន៍ដែលធ្វើដោយដៃ | ❑ វិធីសាស្ត្រមួយដែលហាក់ដូចជាស្ថានភាពពិតនៃជីវិត ដោយប្រើប្រាស់នូវឧបករណ៍ និងសញ្ញាផ្សេងៗដែលអ្នករៀនអាចមានលទ្ធភាពទទួលបាន ឬតម្រូវឱ្យប្រើនៅក្នុងការងារ<br>❑ វាសាកសមបំផុតសម្រាប់ផ្សារភ្ជាប់ការរៀនឱ្យមានចលនា (តម្រូវឱ្យមានសកម្មភាពផ្សារភ្ជាប់ជាមួយការគិត) |

(ប្រភព: Hassell-Corbiell (2001). *Developing Training Courses*)

ខាងក្រោមនេះបង្ហាញថា ភាពជាក់ស្តែងកើនឡើងជាមួយនឹងការប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលដែលខិតទៅជិតស្ថានភាពពិតនៃជីវិត ។ វាសមនឹងនិយាយថា ភាពជាក់ស្តែងមានកាន់តែច្រើន នោះសិក្ខាកាមកាន់តែងាយស្រួលយល់ពីខ្លឹមសារនៃវគ្គបណ្តុះបណ្តាល ។

**គំនូសតាងទី៩: កម្រិតនៃភាពជាក់ស្តែងជាមួយនឹងវិធីសាស្ត្របណ្តុះបណ្តាល**




(ប្រភព: Hassell-Corbiell (2001). *Developing Training Courses*)

វិធីសាស្ត្របណ្តុះបណ្តាល

ការធ្វើលំហាត់ជាក្រុមអាចត្រូវបានគេប្រើដើម្បីផ្តល់ឱកាសឱ្យសិក្ខាកាមចែករំលែកនូវគំនិត និងបទពិសោធន៍ទៅលើបញ្ហាជាក់លាក់នានា ។ វិធីសាស្ត្រនេះគឺមានប្រសិទ្ធិភាពក្នុងការទទួលបាននូវចំណេះដឹង និងយកចំណេះដឹងនេះទៅអនុវត្ត និងផ្លាស់ប្តូរអាកប្បកិរិយាចំពោះការងាររបស់ពួកគេ ។ តារាងខាងក្រោមបង្ហាញពីដំណើរការនៃការធ្វើលំហាត់ ។

## តារាងទី១២: វិធីសាស្ត្របណ្តុះបណ្តាលសម្រាប់ធ្វើលំហាត់

| វិធីសាស្ត្រ | ខ្លឹមសារ |
|---|---|
| គោលបំណង ដែលបានកំណត់ | ❑ ប្រភេទនៃការរៀនសម្រាប់ពិន្ទុបង្រៀនមានៈ<br>១. ការរំលឹក (នូវហេតុការណ៍ ឬដំណើរការ)<br>២. ការយល់ (នូវគោលការណ៍ ឬស្ថានភាព) និង<br>៣. ការអនុវត្តន៏ (សកម្មភាព) |
| បញ្ហា | ❑ មានធាតុ២នៅទីនេះៈ (១) ជ្រើសរើសសំណួរ ឧទាហរណ៏ ឬស្ថានភាព និង (២) ពិពណ៌នាវា<br>❑ ឧទាហរណ៏គួរតែសមស្របសម្រាប់សិក្ខាកាមទាំងអស់ ហើយជម្រើសគួរតែត្រូវបានកំណត់ដោយអ្វីដែលអ្នកដឹងពីសិក្ខាកាម<br>❑ ពិពណ៌នាថាបញ្ហាជាស្នូលនៃលំហាត់ ។ ពិចារណាឱ្យបានហ្មត់ចត់ថាគួបញ្ចូលព័តិមានប៉ុណ្ណាកុំឱ្យតិចពេក ហើយសិក្ខាកាមត្រូវធ្វើការសម្រេចចិត្តដើម្បីបង្កើននូវចំនួនដំណោះស្រាយកុំឱ្យច្រើនពេក ហើយកុំឱ្យឧទាហរណ៏នោះស្មុគស្មាញពេកដែលជាហេតុធ្វើឱ្យសិក្ខាកាមច្រលំ ឬក៏ដំណោះស្រាយនោះជាក់ស្តែងពេក ឬងាយស្រួលពេក ។ |
| ដំណោះស្រាយ ដែលបានប្រឌិតឡើង | ❑ នៅពេលដែលមានដំណោះស្រាយត្រឹមត្រូវតែមួយ សូមពន្យល់វាឱ្យសាមញ្ញតាមដែលអាចធ្វើទៅបាន ហើយប្រសិនបើអាចធ្វើបាន សូមពន្យល់ពីវិធីសាស្ត្រដែលអាចសម្រេចបាននូវដំណោះស្រាយនោះ<br>❑ នៅពេលដែលគ្មានចម្លើយត្រឹមត្រូវ សូមនិយាយថាគ្មានចម្លើយត្រឹមត្រូវ ហើយគួរស្នើនូវដំណោះស្រាយមួយ ។ អ្នកអាចផ្តល់នូវដំណោះស្រាយច្រើន ដូចនេះសូមធ្វើការប្រៀបធៀបនូវចំណុចល្អ និងចំណុចអាក្រក់ តែសូមកុំឱ្យមានភាពស្មុគស្មាញពេក ។ |
| រៀបចំការណែនាំ | ❑ រៀបចំណែនាំដល់សិក្ខាកាមពីរបៀបធ្វើលំហាត់ និងបង្កើតលំហាត់ ។ ការណែនាំនោះត្រូវតែច្បាស់ ហើយងាយស្រួលយល់ និងងាយស្រួលធ្វើ ។<br>❑ គួរណែនាំសិក្ខាកាមឱ្យបានលម្អិតដើម្បីឱ្យគាត់អាចបង្កើតលំហាត់នោះដោយប្រើប្រាស់ពេលវេលាអប្បបរមា<br>❑ ទម្រង់ណែនាំគំរូមានប្រយោជន៏ក្នុងការធានាថា មិនមានការភ្លេចភ្លាំងក្នុងការណែនាំអ្វីៗដែលសំខាន់នោះទេ |
| ធ្វើលំហាត់សាកល្បង | ❑ ការខិតទៅជិតក្រុមគោលដៅ គឺការកំណត់ក្រុមគោលដៅ ។ ទោះបីជាមិនអាចធ្វើការកំណត់បានក៏ដោយ សូមធ្វើតេស្តសាកល្បងទៅលើនរណាម្នាក់<br>❑ វាគួរឱ្យអស្ចារ្យណាស់ដែលលំហាត់មួយមើលទៅវាដូចជាមានហេតុផលល្អណាស់នៅលើក្រដាស |

- ចំណុចនានាដែលត្រូវធ្វើតេស្តមានៈ

*-តើលំហាត់នោះសម្រេចនូវគោលបំណងរបស់វាយ៉ាងល្អដោយរបៀបម៉េច*

*-តើមានភាពងាយស្រួលយ៉ាងម៉េចដល់សិក្ខាកាមក្នុងការយល់បាននូវការណែនាំរបស់យើង*

*-តើមានភាពងាយស្រួលយ៉ាងម៉េចដល់សិក្ខាកាមអាចបំពេញនូវលំហាត់*

*-តើដំណោះស្រាយនោះល្អប៉ុណ្ណា*

*-ត្រូវបានពន្យល់ចប់សពគ្រប់*

*-រយៈពេល និងទីតាំងសម្រាប់ធ្វើលំហាត់*

ឧទាហរណ៍ នៃការណែនាំ របស់គ្រូ ក្នុងការធ្វើ លំហាត់

គំរូនៃការណែនាំរបស់គ្រូក្នុងការធ្វើលំហាត់ត្រូវបានបង្ហាញជូនខាងក្រោម ។ វាត្រូវបានគេប្រើប្រាស់ដើម្បីរៀបចំប្លង់សម្រាប់ធ្វើលំហាត់តាមចំណុចនានាខាងលើ ។

**គំនូសតាងទី១០: គំរូនៃការណែនាំរបស់គ្រូក្នុងការធ្វើលំហាត់**

**១. វគ្គបណ្តុះបណ្តាល**

**២. លំហាត់**

**៣. ទីតាំង**

**៤. ទម្រង់** — ជាបុគ្គល ជាគូ ជាក្រុមគ្នា៣នាក់ ជាក្រុមតូច ជាក្រុមសម្រាប់ទាំងអស់គ្នា

**៥. រយៈពេល**

**៦. សម្ភារៈ/ឧបករណ៍ផ្សេងៗ**

**៧. គោលបំណងចម្បង**

**៨. គោលបំណងផ្សេងៗទៀត**

**៩. ការរៀបចំ**

**១០.ធ្វើលំហាត់**

**១១.បញ្ហាដែលជាសក្តានុពល**



សម្ភារៈ បណ្តុះបណ្តាល

សម្ភារៈបណ្តុះបណ្តាលជាជំនួយក្នុងការអនុវត្តវិធីសាស្ត្របណ្តុះបណ្តាល ។ ខាងក្រោមនេះជាទិដ្ឋភាពទូទៅនៃសម្ភារៈបណ្តុះបណ្តាលដែលអ្នកប្រើប្រាស់ញឹកញាប់ជាងគេ ។ សម្ភារៈបណ្តុះបណ្តាលភាគច្រើនអនុវត្តចំពោះការផ្តល់បទឧទ្ទេសនាមនៅក្នុងថ្នាក់រៀនផង និងការផ្តល់បទឧទ្ទេសនាមតាមអេឡិចត្រូនិចផង ។

**តារាងទី១៣: សម្ភារៈបណ្តុះបណ្តាល**

| សម្ភារៈ | ខ្លឹមសារ |
|---|---|
| សម្ភារៈសម្រាប់បណ្តុះបណ្តាល | ❑ ជាទូទៅវាមានរាងជាសៀវភៅ ឬជាឯកសារចងក្រងរួមមានឯកសារសម្រាប់គ្រូ និងឯកសារសម្រាប់សិស្ស ។ សម្ភារៈទាំងនោះមានដូចជា សន្ទានុក្រម គោលការណ៍នានា នីតិវិធីនានា ការណែនាំ និងឯកសារផ្សេងៗទៀត ។<br>❑ សម្ភារៈសម្រាប់បណ្តុះបណ្តាល ជាទូទៅត្រូវបានគេផ្តល់ជូននៅពេលចាប់ផ្តើមវគ្គ ។ វាអាចត្រូវបានគេឱ្យខ្ចី ឬផ្តល់ជូនជាឯកសារផ្ទាល់ខ្លួនសម្រាប់អ្នករៀននីមួយៗ |
| ឯកសារសម្រាប់ចែក | ❑ ជាឯកសារខ្លីៗដែលត្រូវបានចែកជូននៅពេលត្រូវការ ដូចជានៅពេលធ្វើលំហាត់ ការធ្វើកិច្ចការ និង បញ្ជី ឬតារាង ។<br>❑ ប្រសិនបើមានឯកសារច្រើន សូមចែកឯកសារសម្រាប់ចែកមុន ហើយបន្ទាប់មកបញ្ចូលឯកសារនោះនៅក្នុងឯកសារផ្សេងទៀតផងដែរ<br>❑ វិធីសាស្ត្រនេះគឺដើម្បីធានាថាអ្នករាល់គ្នាមានឯកសារ ហើយសន្សំសំចៃពេលវេលាទៀតផង |
| ក្រដាសអូវើហេត | ❑ ក្រដាសថ្លាដែលអាចប្រើបានជាមួយនឹងម៉ាស៊ីនព្រីន និងម៉ាស៊ីនថតចម្លងឯកសារ ដូចជាចំណែកនៃក្រដាស ។ ក្រដាសនេះត្រូវបានគេប្រើប្រាស់ដើម្បីពង្រីកនូវឯកសារឱ្យធំ ឬដើម្បីបង្ហាញនូវគំនូសតាងនានា លំហូរនៃសកម្មភាព ឬជាក្រដាសម្យ៉ាងដែលគេសម្រាប់បញ្ចាំងស្លៃដល់ថ្នាក់រៀនទាំងមូល<br>❑ ការប្រើប្រាស់នូវក្រដាសនេះ ទាមទារឱ្យមានម៉ាស៊ីនសម្រាប់បញ្ចាំងពន្លឺមួយ ។ អង្គការមួយចំនួនមានម៉ាស៊ីនសម្រាប់បញ្ចាំងពន្លឺនេះមួយ ។<br>❑ អ្នកក៏អាចគ្របក្រដាសថ្លានៅពីលើម៉ាស៊ីនបញ្ចាំងពន្លឺផងដែរ |
| វីដេអូ | ❑ រួមមានខ្សែអាត់ដែលគេចាក់នៅក្នុងម៉ាស៊ីនថតវីដេអូ<br>❑ វីដេអូគឺវាសមស្របសម្រាប់ការបង្ហាញពីនីតិវិធី ឧបករណ៍ និងអត្តចរិកដែលពិបាក ក្នុងការពិពណ៌នា |

(ប្រភព: Hassell-Corbiell (2001). *Developing Training Courses*)

សកម្មភាពនានាសុទ្ធសុឹងជាការរៀនសូត្រ ។ សកម្មភាពមួយៗគួររួមមាន ទិសដៅសម្រាប់គ្រូដូចជា គោលបំណងនៃសកម្មភាព ពេលវេលាសម្រាប់សកម្មភាព របៀបចាត់ចែងសកម្មភាព និងចម្លើយដែលបានស្នើឡើង ។ ការណែនាំសិក្ខាកាមគួរត្រូវបានគេបញ្ចូលនូវសកម្មភាព និងពេលវេលាជូនដល់សិក្ខាកាម ។

# 6 ដំណាក់កាលទី៤: បង្កើតឯកសារបណ្ដុះបណ្ដាល

ដំណាក់កាលទី៤នេះគឺត្រូវបង្កើតឯកសារបណ្ដុះបណ្ដាល ។ បន្ទាប់ពីបានកំណត់វិធីសាស្ត្របណ្ដុះបណ្ដាល និងឯកសារបណ្ដុះបណ្ដាលរួចមក ឯកសារបណ្ដុះបណ្ដាលគួរត្រូវបានបង្កើត ។ គ្រូឧទ្ទេសមិនត្រឹមតែជាអ្នកនិយាយប៉ុណ្ណោះទេ តែក៏ជាអ្នកនិពន្ធនូវឯកសារផងដែរ ។






បន្ទាប់ពីបានកំណត់ ថាហេតុអ្វីបានជាគេត្រូវការវា? នរណានឹងអានវា? គេនឹងត្រូវការវានៅពេលណា តើគេនឹងសរសេរវានៅកន្លែងណា? តើមានបញ្ចូលចំណុចណាខ្លះ? នៅដំណាក់កាលដំបូងនៃការបង្កើតឯសារបណ្ដុះបណ្ដាលរួចមក យើងត្រូវធ្វើការសម្រេចចិត្តយកចំណុចចម្បងរបស់យើង ហើយបន្ទាប់មកត្រូវគិតថាយើងចង់ធ្វើអ្វី ។ ពេលខ្លះគេអាចយល់បាន បើយើងមិនទាន់សរសេរចំណុចចម្បង រហូតដល់ពេលមានទិន្នន័យគ្រប់គ្រាន់ទើបសម្រេច ។

មានបច្ចេកទេសជាច្រើនដើម្បីជួយអ្នកក្នុងការបង្កើតប្លង់នៃការសរសេររបស់អ្នក ។ វិធីសាស្ត្រដែលសាមញ្ញបំផុតនោះគឺគ្រាន់តែរាយមុខនូវចំណុចនានា ហើយបន្ទាប់មកដាក់លេខរៀងវា ឬក៏បិទស្ទីកគ័រនៅលើចំណុចនីមួយៗ ។ ដូចនេះចំណុចទាំងនេះបង្កើតបានជាផ្នែក ឬកថាខណ្ឌផ្សេងៗគ្នា ។ បច្ចេកទេសផ្សេងទៀតគឺគេប្រើក្រដាសផ្ទាំងធំ និងផែនទី ។ បញ្ជីសរសេរសម្រាប់អាន ត្រូវបានបង្ហាញជូនដូចខាងក្រោមនេះ ។

សរសេរសម្រាប់អាន

## គំនូសតាងទី១១: បញ្ជីសរសេរសម្រាប់អាន

- ❑ តើអ្នកគួរតែសរសេរទាំងអស់ឬអត់?
- ❑ នរណាជាអ្នកអានការសរសេររបស់អ្នក?
- ❑ តើអ្នកបានដឹងច្បាស់ពីអ្នកអានរបស់អ្នកឬទេ?
- ❑ តើអ្វីជាគោលបំណងរបស់អ្នកទាក់ទងនឹងអត្តចរិត?
- ❑ តើត្រូវដោះស្រាយទំនាស់នៃអ្នកអានដោយរបៀបម៉េច?
- ❑ តើអ្នកចង់ប្រើប្រាស់ទម្រង់អ្វី?
- ❑ តើអ្នកចង់សរសេររបៀបម៉េច? ឬចង់ដាក់ពណ៌អ្វី?
- ❑ តើនៅពេលណាដែលអ្នកសរសេរបានល្អ?
- ❑ តើនៅកន្លែងណាដែលអ្នកសរសេរបានល្អ?
- ❑ តើអ្វីជាចំណុចចម្បងរបស់អ្នក? តើអ្នកនឹងសរសេរវានៅកន្លែងណា?
- ❑ តើមានចំណុចអ្វីផ្សេងទៀតដែលអ្នកចង់បញ្ចូល?
- ❑ តើអ្នកនឹងបង្កើតប្លង់វាដោយរបៀបម៉េច?



(ប្រភព: Stimson (2005). *How to Write and Prepare Training Materials*)

ការប្រើពាក្យដែលមានឥទ្ធិពល

របៀបសរសេរវាសំខាន់ក្នុងការចៀសវាងការប្រើពាក្យខុសដែលនាំឱ្យមានការភាន់ច្រលំ ។ វិធីសាស្ត្រសរសេរដែលល្អបំផុតគឺការប្រើឃ្លាខ្លី ហើយសាមញ្ញ ។ សេចក្តីណែនាំមួយចំនួនដែលមានអត្ថប្រយោជន៍មានបង្ហាញខាងក្រោម:

## គំនូសតាងទី១២ៈ ការណែនាំក្នុងការប្រើប្រាស់ពាក្យពេចន៍



- លុបចោលនូវពាក្យដែលមិនចាំបាច់ ។
- ចៀសវាងការប្រើភាសាមិនត្រូវ ។
- ប្រើប្រាស់ពាក្យពេចន៍ដែលបង្ហាញពីភាពវិជ្ជមានជាជាងអវិជ្ជមាន ។
- ប្រើប្រាស់នាមរូបិយជាជាងអរូបិយ ។
- ប្រើប្រាស់កិរិយាស័ព្ទជាជាងនាម ។
- ប្រើប្រាស់កិរិយាស័ព្ទក្នុងទម្រង់សកម្មជាជាងអកម្ម ។
- ប្រើប្រាស់សព្វនាមបុរសទី១ និងទី២ (ខ្ញុំ និងអ្នក) ។

(ប្រភពៈ Stimson (2005). *How to Write and Prepare Training Materials*)

**ការបង្ហាញឯកសារបណ្តុះបណ្តាល**

សព្វថ្ងៃនេះ ការសរសេរភាគច្រើន គេប្រើប្រាស់ស្លៃបង្ហាញ ។ បញ្ជីសម្រាប់ធ្វើឯកសារបង្ហាញមានដូចខាងក្រោម ។

## គំនូសតាងទី១៣ៈ បញ្ជីសម្រាប់ត្រួតពិនិត្យឯកសារបង្ហាញ



- ❑ ពិចារណាអំពីរូបរាងនៃឯកសាររបស់អ្នក ?
- ❑ ដកឃ្លា ?
- ❑ មានប្រធានបទចម្បងមួយក្នុងមួយកថាខណ្ឌ ?
- ❑ ចាប់ផ្តើមកថាខណ្ឌនីមួយៗដោយប្រើសញ្ញាផ្សេងៗ ?
- ❑ ប្រើប្រាស់ចំណងជើង ?
- ❑ ដាក់លេខរៀងឱ្យស្របគ្នា ?
- ❑ ធ្វើបញ្ជីនានាឱ្យមានប្រសិទ្ធិភាព ?
- ❑ ដាក់លេខឱ្យបានសាមញ្ញបំផុត ?
- ❑ ប្រើប្រាស់តារាង និងសរសរ (chart)?
- ❑ ដាក់បញ្ចូលនូវព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ ?
- ❑ ប្រើប្រាស់ការបញ្ជាក់បង្ហាញ ឬពណ៌?
- ❑ ប្រើប្រាស់គំនូសចលនា ?
- ❑ ប្រើប្រាស់រូបភាព ?
- ❑ សម្របការងាររបស់អ្នកទៅលើក្រដាស ឬស្លៃបង្ហាញ

(ប្រភព: Stimson (2005). *How to Write and Prepare Training Materials*)

ប្រភេទឯកសារបណ្តុះបណ្តាល

មានឯកសារបណ្តុះបណ្តាល៣ ទៅ៤ប្រភេទដែលត្រូវបានប្រើប្រាស់សម្រាប់វគ្គបណ្តុះបណ្តាលៈ (១) អត្ថបទសៀវភៅ (២) ឯកសារបង្ហាញ (ដូចជាឯកសារដែលធ្វើដោយស្លែបង្ហាញ) (៣) កំណត់ចំណាំរបស់គ្រូ និង (៤) ឯកសារសម្រាប់ចែក ។

អត្ថបទសៀវភៅ

ឯកសារបណ្តុះបណ្តាលដែលសំខាន់ត្រូវបង្កើតមុនគេគឺ អត្ថបទសៀវភៅដែលមានការគូសបញ្ជាក់ដែលជាជំនួយដល់អ្នករៀន ។ អត្ថបទចំនែកនៃការផ្តល់ព័តិមានដល់អត្ថបទសៀវភៅ ។ គោលការណ៍នានាក្នុងការសរសេរគឺដូចគ្នាទាំងអស់ ។ មានសំណួរគន្លឹះមួយសួរថា តើអ្នកបញ្ចូលនូវព័តិមានប៉ុណ្ណា ? ចម្លើយគឺថា ចង់សរសេរច្រើនតាមដែលអ្នកចង់ឱ្យអ្នករៀនសម្រេចបាននូវគោលបំណង ។ កាលណាគោលបំណង នៃការសរសេរកាន់តែជាក់លាក់ នោះការសរសេរអត្ថបទកាន់តែងាយស្រួល ។

អត្ថបទសៀវភៅ

***អត្ថបទ*** គួរត្រូវបានគេសរសេរដោយខ្លី ងាយស្រួលអាន ហើយប្រើពាក្យ ប្រយោគ និងកថាខណ្ឌយ៉ាងសាមញ្ញ ។ ជាពិសេស សូមឱ្យច្បាស់ថាកថាខណ្ឌនីមួយៗបង្កើតបានតែមួយចំណុចទេ ។ កថាខណ្ឌដែលមានប្រយោគតែមួយមួយចំនួនមានលក្ខណៈប្រសើរជាងកថាខណ្ឌដែលមានប្រយោគច្រើន ក្នុងការបង្កើតឯកសារសម្រាប់រៀនដោយខ្លួនឯង។ ហើយការប្រើចំណុចដុំមូល ឬក៏ការដាក់លេខរៀងធ្វើឱ្យសិក្ខាកាមអាចធ្វើការកំណត់វែកញែកបាន។

អត្ថបទមិនមែនគ្រាន់តែជាវិធីមួយនៃការផ្តល់ព័តិមាននោះទេ ។ ក្រាភិច និងគំនូសខ្សែបន្ទាត់ត្រូវបានគេប្រើមិនមែនសម្រាប់តែគូសបញ្ជាក់នូវចំណុចនានានោះទេ តែថែមទាំងគូសបញ្ជាក់នូវអ្វីដែលសិក្ខាកាមត្រូវតែរៀនផងដែរ ។

***ការសង្ខេប និងបញ្ជីសម្រាប់ត្រួតពិនិត្យ*** ជួយសិស្សដោយផ្តល់នូវៈ

- ❑ ឯកសារសង្ខេបនូវអ្វីដែលមាន
- ❑ ការនិយាយពាក្យសួនៈ គំរូបញ្ជីសម្រាប់ត្រួតពិនិត្យស៊ីគ្នានឹងពាក្យសុភាសិតថា "ដំបូងអ្នកប្រាប់ពួកគេនូវអ្វីដែលអ្នកនឹងប្រាប់ពួកគេ បន្ទាប់មកអ្នកប្រាប់ពួកគេ ហើយបន្ទាប់មកទៀតអ្នកប្រាប់ពួកគេនូវអ្វីដែលអ្នកបានប្រាប់ពួកគេ" ។
- ❑ ផ្អាកអានបន្តិចដោយសារតែការសង្ខេប និងបញ្ជីសម្រាប់ត្រួតពិនិត្យមានទម្រង់ផ្សេងគ្នា

ហើយភាពខុសគ្នានេះធ្វើឱ្យអ្នកអានមានការប្រែប្រួលល្បឿននៃការអាន ។

ការបង្ហាញ

មានឧបករណ៍សម្រាប់បង្ហាញជាច្រើនដូចជា ក្រដាសផ្លាស្ទិចថ្លា ស្លៃដែលបញ្ចាំងដោយកុំព្យូទ័រ ។ ស្លៃដែលបញ្ចាំងដោយកុំព្យូទ័រត្រូវបានគេប្រើច្រើនឡើងៗជាមួយនឹងការបញ្ចាំងរូបភាពផ្សេងៗ ។ ការណែនាំសម្រាប់ផលិតឧបករណ៍សម្រាប់បង្ហាញមានបង្ហាញជូនខាងក្រោមៈ

- ❑ រៀបចំអត្ថបទឱ្យខ្លី ហើយសាមញ្ញ
- ❑ ចៀសវាងការប្រើប្រាស់អក្សរទាំងអស់ គួរប្រើរូបភាពខ្លះដែរ
- ❑ ប្រើពណ៌ដើម្បីងាយស្រួលមើល

មានឧបករណ៍សម្រាប់ជំនួយផ្សេងទៀតដូចជា ***ក្រដាសផ្ទាំងធំ និងផុសស្ទ័រ (poster)*** ។ មុខងារចម្បងនៃក្រដាសផ្ទាំងធំ ក្តារខៀនពណ៌ស និងពណ៌ខ្មៅអាចឱ្យគ្រូប្រើប្រាស់នៅក្នុងវគ្គដើម្បីជាជំនួយដល់ការមើលរបស់សិក្ខាកាមនៅក្នុងវគ្គផងដែរ ។ ក្រដាសផ្ទាំងធំអាចត្រូវបានគេប្រើប្រាស់សម្រាប់ឯកសារដែលបានរៀបចំរួច ។ ការសរសេរត្រូវតែឱ្យមើលដាច់ ហើយវាមានការលំបាកក្នុងការសរសេរឱ្យមានរបៀបរៀបរយនៅលើក្តារខៀន ជាងការសរសេរនៅលើក្រដាសផ្ទាំងធំ ។

ផុសស្ទ័រ (poster) ជាចំណុចសំខាន់សម្រាប់បទឧទ្ទេសនាម ឬការពិភាក្សា ។ ដូចនេះគេចាំបាច់មានភាពពូកែក្នុងការរក្សាបាននូវការយកចិត្តទុកដាក់របស់សិស្ស ។ ចូរចងចាំនូវវិន័យ និងភាពងាយស្រួលរូបភាព និងពណ៌ ។ ផុសស្ទ័រធ្វើឱ្យសិក្ខាកាមចងចាំជាអចិន្ត្រៃយ៍ ។ ផុសស្ទ័រក៏សមស្របសម្រាប់រៀបចំបួងពិភាក្សានៅក្នុងវគ្គផងដែរ ។

កំណត់បង្ហាញ
របស់គ្រូ

**កំណត់បង្ហាញរបស់គ្រូ** ត្រូវបានគេហៅជាញឹកញាប់ថាផែនការមេរៀន ឬផែនការបង្រៀន ។ ផែនការទាំងនេះអាចត្រូវបានគេសរសេរនៅលើសៀវភៅ ឬក្រដាស ។ ប្រើប្រាស់វិធីសាស្ត្រមួយដែលគេហៅថា វិធីសាស្ត្រ four-column ។ វិធីសាស្ត្រនេះមានគូឡោន៤សម្រាប់ពេលវេលា ខ្លឹមសារលំហាត់ និងប្រដាប់ជំនួយសម្លេង ។ ឯកសារសម្រាប់បង្ហាញភាគច្រើនមានកន្លែងសម្រាប់សរសេរកំណត់បង្ហាញ របស់គ្រូ ។

គោលបំណងនៃកំណត់បង្ហាញរបស់គ្រូខាងក្រោមនេះអាចឱ្យគ្រូរៀបចំវគ្គបាន ។ ចំណុចនានាដែលត្រូវពិចារណាសម្រាប់រៀបចំវគ្គមានរៀបរាប់ជូនខាងក្រោមៈ

- ❑ សរសេរគោលបំណងវគ្គ

- ស្វែងរកពីរបៀបធ្វើតេស្តឱ្យសម្រេចបាននូវគោលបំណងនានាទាំងនេះ
- កំណត់ថាអ្វីដែលសិក្ខាកាមត្រូវតែដឹងដើម្បីសរសេរកំណត់បង្ហាញ
- ចាប់ផ្តើមធ្វើបទបង្ហាញដោយបង្កើតឱ្យមានការចាប់អារម្មណ៍
- ធ្វើការណែនាំខ្លួនឱ្យបានលឿន ដោយឱ្យសិក្ខាកាមនិយាយ ឬក៏ធ្វើសកម្មភាពផ្សេងៗ
- បង្កើតបញ្ជីមួយដោយដាក់ចំណងជើងថា"ត្រូវតែដឹង" (និងព័ត៌មានផ្សេងទៀតដែលអ្នកសម្រេចចិត្តដាក់បញ្ចូលដែរ)
- សង្ខេបឱ្យបានញឹកញាប់
- ធ្វើឱ្យយល់នូវទំនាក់ទំនងរវាងប្រធានបទខុសៗគ្នា
- ជ្រើសរើសបច្ចេកទេស និងឧបករណ៍ជំនួយសម្លេងដើម្បីពង្រឹងចំណុចនីមួយៗនៃវគ្គ
- កំណត់បង្ហាញដោយគូសបញ្ជាក់ពីទំនាក់ទំនងទៅនឹងស្ថានភាពការងារ

គ្រូៗជាច្រើនមានវិធីសាស្រ្តរៀងៗខ្លួនក្នុងការបង្កើតកំណត់ចំណាំរបស់គេ តែទោះជាក្នុងទម្រង់ណាក៏ដោយ ក៏ព័ត៌មានខាងក្រោមគួរតែត្រូវបានបញ្ចូលៈ

- ខ្លឹមសារជាមូលដ្ឋាន និងវិធីសាស្រ្តដែលត្រូវបានប្រើប្រាស់ (ឧ. បទឧទ្ទេសនាម សំណួរ និងចម្លើយ ។ល។)
- ទំនាក់ទំនងរវាងខ្លឹមសារ ឧបករណ៍ជំនួយការស្តាប់ ឯកសារចែក និងលំហាត់នានា
- ការត្រួតពិនិត្យពីពេលវេលា

## គំនូសតាងទី១៤ៈ គំរូកំណត់បង្ហាញរបស់គ្រូ

កំណត់បង្ហាញរបស់គ្រូ

### ១. វិមជ្ឈការ និងវិសហមជ្ឈការ

១) តើអ្វីទៅជាវិមជ្ឈការ?

២) តើអ្វីទៅជាវិសហមជ្ឈការ?

៣) តើវិមជ្ឈការ និងវិសហមជ្ឈការខុសគ្នាដូចម្តេច?

**វិមជ្ឈការ** :គឺជាការផ្ទេរអំណាច និងការទទួលខុសត្រូវពីរដ្ឋបាលកណ្តាលទៅឱ្យរដ្ឋបាលមូលដ្ឋាន ដើម្បីគ្រប់គ្រង ទទួលខុសត្រូវទៅលើធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្ស ។

**វិសហមជ្ឈការ** :គឺជាការធ្វើប្រតិភូកម្មអំណាចពីរដ្ឋបាលថ្នាក់កណ្តាល ទៅឱ្យអាជ្ញាធរមូលដ្ឋាន "ការិយាល័យ មន្ទីនៃអាជ្ញាធរមូលដ្ឋាន" ដើម្បីអនុវត្តមុខងារ និងសិទ្ធិអំណាចក្នុងនាមរដ្ឋបាលកណ្តាលតាមរយៈការផ្តល់ធនធាន សេវា និងការកសាងសមត្ថភាព ។

**ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការៈ**

ចំពោះវិមជ្ឈការ អាជ្ញាធរមូលដ្ឋានគួរធ្វើកិច្ចការតាមការណែនាំពីរដ្ឋបាលកណ្តាល ។ ប្រសិនបើមានបញ្ហាកើតឡើង រដ្ឋបាលកណ្តាលជាអ្នកទទួលខុសត្រូវ ។ ចំពោះវិសហមជ្ឈការ អាជ្ញាធរមូលដ្ឋានគួរធ្វើកិច្ចការដោយផ្អែកតាមច្បាប់ ។ ប្រសិនបើមានបញ្ហាកើតឡើង អ្នកទទួលខុសត្រូវគឺអាជ្ញាធរមូលដ្ឋាន ។



ពីដំបូង ព័ត៌មាននេះត្រូវបានគេសរសេរលម្អិតដូចជាផែនការមេរៀន ឬផែនការបង្រៀនដែលត្រូវបានគេធ្វើសម្រាប់គ្រូបង្គោលផ្សេងទៀត ។ ចំណុចនានាដែលត្រូវពិចារណារួមមានៈ

- ❑ ព័ត៌មានអំពីគោលបំណង ឧបករណ៍ និងសម្ភារៈផ្តល់ព័ត៌មានអាចត្រូវបានគេរកឃើញនៅលើផ្នែកដំបូងគេ មិនមែននៅផ្នែកបន្តបន្ទាប់នោះទេ
- ❑ ការចាត់ចែងពេលវេលាអាចត្រូវបានគេប៉ាន់ប្រមាណតាមពេលវេលាជាក់ស្តែង ឬពេលវេលាដែលបានកន្លងទៅនៅដំណាក់កាលដំបូងនៃវគ្គ
- ❑ ខ្លឹមសារអាចងាយស្រួល ឬពិបាកតាមដែលអ្នកចង់បាន ។ ការប្រើពណ៌ផ្សេងៗគ្នាទៅលើបទឧទ្ទេសនាម សំណួរ ចម្លើយ និងសកម្មភាពផ្សេងៗផ្តល់នូវទិដ្ឋភាពទូទៅដ៏មានសារៈសំខាន់មួយសម្រាប់វគ្គ ។
- ❑ ឯកសារសម្រាប់ចែកមានទំនាក់ទំនងជាមួយលំហាត់ ហើយគេអាចមើលឯកសារនោះនៅត្រង់តារាងលំហាត់ផងដែរ ។ វាមានសារៈសំខាន់ក្នុងការដាក់លេខ ឬ អក្សរដើម្បីជាចំណាំ ។

***ផែនការមេរៀន*** អាចត្រូវបានគេសរសេរដើម្បីកត់សំគាល់នៅក្នុងស្លៃបង្ហាញ ។ ផែនការមេរៀននេះមានសារៈសំខាន់ ហើយបានប្រែក្លាយជាស្តង់ដាទូទៅមួយក្នុងរយៈពេល០២ ទៅ០៣ឆ្នាំកន្លងទៅនេះ តែទោះជាយ៉ាងណាក៏ដោយ វាត្រូវបានគេសរសេរនៅក្នុងស្លៃ ដូចនេះហើយទើបមានការប្រើប្រាស់ឧបករណ៍ជំនួយច្រើន ។ ផែនការមេរៀនត្រូវបានគេប្រើប្រាស់យ៉ាងល្អបំផុតដោយៈ

- ❑ ពិចារណាទៅលើរចនាសម្ព័ន្ធនៃបទបង្ហាញ និងវគ្គ
- ❑ កំណត់នូវប្រភេទនៃវិធីសាស្ត្រធ្វើបទបង្ហាញ សកម្មភាព ឬ ឧបករណ៍ជំនួយក្នុងការស្តាប់
- ❑ ប្រើប្រាស់នូវសម្ភារៈសម្រាប់ធ្វើបទឧទ្ទេសនាមរួមមានផែនការមេរៀនដែលបានកត់សំគាល់នៅក្នុងស្លៃនីមួយៗផងដែរ

**គំនូសតាងទី១៥ៈ គំរូផែនការមេរៀន**

**ផែនការមេរៀន**

**ចំណងជើងៈ** វគ្គបណ្ដុះបណ្ដាលអំពីរដ្ឋបាលមូលដ្ឋាន

**គោលបំណងៈ** សិក្ខាកាមនឹងបានកែលម្អកម្រិតយល់ដឹងអំពីរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

**ឧបករណ៍ៈ** ម៉ាស៊ីនបញ្ចាំងពន្លឺ ក្រដាសផ្ទាំងធំ ម៉ាស៊ីនថតវីដេអូ កុំព្យូទ័ រម៉ាស៊ីនថតរូប

**សម្ភារៈ** ប៊ិច ក្រដាស ស្កុត

| ពេលវេលា | ឃ្លឹមសារ | លំហាត់ | ឧបករណ៍/សម្ភារៈជំនួយ |
|---|---|---|---|
| ៩:០០ | មតិស្វាគមន៍ ណែនាំខ្លួន ពន្យល់ពីវគ្គនីមួយៗ | | |
| ៩:៣០ | បទឧទ្ទេសនាមអំពីរដ្ឋបាលមូលដ្ឋាន | | ម៉ាស៊ីនបញ្ចាំងស្លៃ |
| ១០:៣០ | សំណួរ និងចម្លើយ | | ក្រដាសផ្ទាំងធំ |
| ------ | | | |
| ១៥:០០ | ភាពខុសគ្នានៃរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន | ការងារជាក្រុម | ក្រដាស ប៊ិច ស្កុត |

ឯកសារ
សម្រាប់ចែក

មានវិធីជាច្រើនក្នុងការចែកឯកសាររួមមានៈ ឯកសារដែលរៀបចំដោយគ្រូ ឯកសារដែលរៀបចំដោយសិក្ខាកាមខ្លួនឯង និងវិធីសាស្ត្រនៃការបញ្ចូលគ្នា ។ វិធីដ៏ងាយស្រួលមួយក្នុងការបង្កើតឯកសារចែកនេះ គឺត្រូវធ្វើដោយផ្អែកលើឯកសារផ្សេងៗដោយទុកចន្លោះទំនេរសងខាង ឬនៅខាងមុខដើម្បីឱ្យសិក្ខាកាម អាចសរសេរកំណត់ចំណាំបាន ។

***ឯកសារដែលរៀបចំដោយគ្រូ*** ដូចជាស្លៃបង្ហាញគួរធ្វើឱ្យខ្លីហើយសាមញ្ញ ដែលផ្ទុកនូវព័ត៌មានចាំបាច់សម្រាប់សិក្ខាកាមផង និងខ្លួនឯងផង ។ ចំណុចដែលត្រូវពិចារណាមានដូចខាងក្រោមៈ

- ❑ ប្លង់ព័ត៌មានដើម្បីឱ្យសិក្ខាកាមអាចប្រើប្រាស់ និងយោងទៅលើវាដោយងាយស្រួល ។
- ❑ កុំភ្លេចចំណងជើង ។
- ❑ សរសេរកថាខណ្ឌខ្លី ឃ្លាខ្លី និងពាក្យខ្លី ។
- ❑ សរសេរសំណង់ប្រយោគរស់រវើក ។
- ❑ ប្រើរូបភាពរួមមានសសរ គំនូសបន្ទាត់ ឬរូបថត ( គ្រាន់តែឱ្យប្រាកដថាគេអាចបង្កើតវាទាំងនោះ

ឡើងវិញបានយ៉ាងច្បាស់) ។

- រចនាស្លៃដើម្បីទាក់ទាញ និងរក្សាបាននូវការយកចិត្តទុកដាក់របស់សិក្ខាកាម ។

គុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតឯកសារទាំងនោះត្រូវបានបង្ហាញជូនខាងក្រោម ។

**គំនូសតាងទី១៦: គុណសម្បត្តិ និងគុណវិបត្តិនៃឯកសារដែលបានរៀបចំដោយគ្រូ**

**គុណសម្បត្តិ**

- អ្នកអាចប្រាកដថាឯកសារទាំងនោះត្រូវបានផលិត និងត្រឹមត្រូវ
- សិក្ខាកាមអាចចំណាយពេលច្រើនក្នុងការរៀនជាជាងគ្រាន់តែកត់នូវពាក្យរបស់គ្រូ

**គុណវិបត្តិ**

- សិក្ខាកាមអាចផ្តោតអារម្មណ៍តិចតួច នៅពេលដែលពួកគេដឹងថាមានឯកសារសម្រាប់ប្រធានបទឧទ្ទេសនាមនោះរួចហើយ
- យើងពិនិត្យឃើញថាសិក្ខាកាមម្នាក់ៗមានតម្រូវការផ្សេងៗគ្នាមិនអាចជៀសរួច គ្មានព័ត៌មានណាមួយដែលផ្តល់នោះ មានផលប្រយោជន៍សម្រាប់ទាំងអស់គ្នានោះទេ
- វាមានការលំបាកក្នុងការរកនូវពេលវេលាសមស្របដើម្បីចែកឯកសារ ។ ហេតុផលគឺថាៈ

  **មុនបណ្តុះបណ្តាលៈ** សិក្ខាកាមមួយចំនួនអាចអានវាមុន តែមួយចំនួនទៀតអត់អានទេ (ចេះដឹងតិច) នឹងមិនធ្វើឱ្យមានភាពខុសប្លែកគ្នាប៉ុន្មានចំពោះចំណេះដឹងបឋមនោះទេ ។ សិក្ខាកាម មួយចំនួនអាចគិតថា ឯកសារចែកនេះជាគ្រឿងបន្ទាប់បន្សំសម្រាប់វគ្គ និងមិនចូលរួមតែម្តង ។

  **អំឡុងពេលបណ្តុះបណ្តាល** សិក្ខាកាមអានឯកសារទាំងនោះ ជាជាងការផ្តោតអារម្មណ៍ទៅលើការធ្វើបទបង្ហាញ ។

  **ក្រោយពេលបណ្តុះបណ្តាលៈ** នៅពេលនេះគឺឱ្យសិក្ខាកាមចងក្រងឯកសារហើយភ្លេចវា

**ឯកសារដែលរៀបចំដោយសិក្ខាកាមខ្លួនឯង** វាផ្ទុយពីឯកសារដែលរៀបចំរួចហើយដោយគ្រូ ។ គុណសម្បត្តិ និងគុណវិបត្តិមានដូចខាងក្រោមៈ

**តំនូសតាងទី១៧: គុណសម្បត្តិ និងគុណវិបត្តិនៃឯកសារដែលរៀបចំដោយសិក្ខាកាមខ្លួនឯង**



**គុណសម្បត្តិ**

- ❑ វាអាចសន្សំសំចៃនូវពេលវេលា និងកិច្ចខិតខំប្រឹងប្រែងរបស់អ្នក (ទោះបីជាយ៉ាងណាក៏ដោយ គេត្រូវការវាទាំងពីរ)
- ❑ ការកត់ត្រាវាមានលក្ខណៈឯកជន ហើយវាមានលក្ខណៈល្អប្រសើរក្នុងការប្រើប្រាស់បន្ទាប់ពីវគ្គ

**គុណវិបត្តិ**

- ❑ សិក្ខាកាមដែលរវល់ មិនមានពេលស្តាប់ គិត ហើយក៏មិនមានពេលសួរដែរ សរុបមកបានត្រឹមតែចូលរៀនទល់មុខគ្រូ
- ❑ ការកត់ត្រា ឬកត់ចំណាំមិនអាចពេញលេញទាំងអស់ទេ

**វិធីសាស្ត្រនៃការបញ្ចូលគ្នា** គឺថាគ្រូផ្តល់នូវប្លង់នៃចំណុចសំខាន់ៗ ហើយទុកចន្លោះទំនេរឱ្យសិក្ខាកាមបំពេញ ឬសរសេរព័ត៌មានបន្ថែមតាមដែលគេចង់បាន ។ ប្លង់នៃចំណុចសំខាន់នោះ គួរមានព័ត៌មានច្រើនជាងចំណងជើងប្រធានបទ និងនូវមុខងារដូចខាងក្រោម។

- ❑ បង្កើតនូវបញ្ជីសម្រាប់ត្រួតពិនិត្យ និងវិន័យឱ្យបានពេញលេញ
- ❑ ប្រើដ្យាក្រាម និងរូបភាពដើម្បីឱ្យមានភាពច្បាស់លាស់នៃឯកសារ និងជួយបន្ថែមការចងចាំ
- ❑ បញ្ចូលនូវឯកសារយោងដែលចាំបាច់ ឬឱ្យប្រាកដថាសិក្ខាកាមអាចទុកវាដោយងាយស្រួល
- ❑ ស្នើឱ្យសិក្ខាកាមកត់សំគាល់នូវបទពិសោធន៍របស់ពួកគេជាមួយនឹងមេរៀន
- ❑ ចូរប្រុងប្រយ័ត្នកុំឱ្យផ្តល់ព័ត៌មានច្រើនពេកដែលនាំឱ្យប្លង់នោះក្លាយទៅជាកំណត់ត្រានានារបស់គ្រូ

សរុបមក វិធីសាស្ត្រនៃការបញ្ចូលគ្នាផ្តល់នូវធាតុសំខាន់ពីរគឺៈ ភាពត្រឹមត្រូវ និង ពេញលេញនៃកំណត់ត្រារបស់គ្រូដែលធ្វើឱ្យសិក្ខាកាមមានភាពផ្ទាល់ខ្លួន និងភាពស្និទស្នាលច្រើន ។ ទោះបីជាយ៉ាងណាក៏ដោយ គុណវិបត្តិធំជាងគេគឺថាវាកំណត់នូវភាពអាចបត់បែនបាននៃវគ្គបណ្តុះបណ្តាល ។ សិក្ខាកាមនឹងរំពឹងថាគ្រូនឹងក្តាប់បាននូវគ្រប់ចំណុចទាំងអស់តាមលំដាប់លំដោយ ក្រុមខ្លះទៀតយល់ថាខ្លួននឹងនឹងផ្តោតទៅលើតែទិដ្ឋភាពមួយចំនួនទេ ។ គ្រូអាចបន្តការពន្យល់ទៅកាន់សិក្ខាកាម និងដឹងច្បាស់ពីការសរសេររបស់អ្នកដើម្បីឱ្យអ្នកអាចនាំសិក្ខាកាមទៅទំព័រដែលត្រឹមត្រូវ ។

PILAC

មានឯកសារ៣ដែលគួររៀបចំៈ (១) អត្ថបទសៀវភៅ (២) ឯកសារសម្រាប់ចែក ឬឯកសារសម្រាប់បង្ហាញ (ស្លៃបង្ហាញ) និង (៣) ឯកសារយោងផ្សេងទៀតដូចជា ប្រកាសដែលទាក់ទងនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ) ។

PILAC

ឯកសារបណ្តុះបណ្តាលសម្រាប់សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែលបានបង្កើតសម្រាប់គម្រោងភីឡាក់នៅដំណាក់កាលទី១ មានបង្ហាញជូនខាងក្រោម ។

## តារាងទី១៤: ឯកសារបណ្តុះបណ្តាលសម្រាប់សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់

| ប្រភេទ | ខ្លឹមសារ |
|---|---|
| អត្ថបទសៀវភៅ | ❑ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ<br>❑ អភិបាលកិច្ចមូលដ្ឋាន និងហិរញ្ញវត្ថុមូលដ្ឋាននៅជប៉ុន |
| ឯកសារសម្រាប់បទបង្ហាញ | ❑ ស្លែបង្ហាញសង្ខេបអំពីគម្រោងភីឡាក់<br>❑ ឯកសារសង្ខេបអំពីគម្រោងភីឡាក់<br>❑ ស្លែបង្ហាញអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ស្លែបង្ហាញអំពីទស្សនៈទាននៃពង្រាងច្បាប់រៀបចំអង្គការ<br>❑ ស្លែបង្ហាញអំពីអភិបាលកិច្ចមូលដ្ឋាន និងហិរញ្ញវត្ថុមូលដ្ឋាននៅជប៉ុន<br>❑ ស្លែបង្ហាញអំពីរដ្ឋបាលដែលផ្តល់សេវាដល់ប្រជាពលរដ្ឋ (ការិយាល័យច្រកចេញចូលតែមួយ)<br>❑ ស្លែបង្ហាញអំពីករណីសិក្សា" ការិយាល័យច្រកចេញចូលតែ១ មួយ" កំណែទម្រង់រដ្ឋបាល<br>❑ ស្លែបង្ហាញអំពីគណនេយ្យភាព និងមន្ត្រីរាជការ<br>❑ ករណីសិក្សា : គណនេយ្យភាព និងមន្ត្រីរាជការ |
| ឯកសារយោង | ❑ ច្បាប់ និង ប្រកាសនានាដែលទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាន<br>▪ វិសោធនកម្មរដ្ឋធម្មនុញ្ញ<br>▪ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ<br>▪ ប្រកាសស្តីពីតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធ អង្គការលេខនៃរដ្ឋបាលខេត្ត និងក្រុង<br>▪ ប្រកាសស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលនៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ សេចក្តីសម្រេចស្តីពីរចនាសម្ព័ន្ធ និងរដ្ឋបាលនៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យ ច្រកចេញចូលតែមួយនៃស្រុក សៀមរាប ខេត្តសៀមរាប |

| | |
|---|---|
| | និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ ប្រកាសស្តីពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងការិយាល័យប្រជាពលរដ្ឋ នៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>❑ ក្របខណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ឯកសារស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា<br>❑ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីគាំទ្រឃុំ-សង្កាត់ |

PILAC

ឯកសារបណ្តុះបណ្តាលមន្ត្រី អ.រ.ម ដែលបានបង្កើតដោយគម្រោងភីឡាក់នៅដំណាក់កាលទី១ មាន បង្ហាញជូនខាងក្រោម ។

**តារាងទី១៥: ឯកសារបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះបណ្តាលមន្ត្រី អ.រ.ម**

| ប្រភេទ | ខ្លឹមសារ |
|---|---|
| អត្ថបទសៀវភៅ | ❑ អភិបាលកិច្ចមូលដ្ឋាន និងហិរញ្ញវត្ថុមូលដ្ឋាននៅជប៉ុន<br>❑ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ |
| ឯកសារសម្រាប់បង្ហាញ | ❑ ស្លាយបង្ហាញសង្ខេបអំពីគម្រោងភីឡាក់<br>❑ ឯកសារសង្ខេបអំពីគម្រោងភីឡាក់<br>❑ ស្លាយបង្ហាញអំពីរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន<br>❑ ស្លាយបង្ហាញអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ស្លាយបង្ហាញអំពីទស្សនៈទាននៃពង្រាងច្បាប់រៀបចំអង្គការ<br>❑ ស្លាយបង្ហាញអំពីទិដ្ឋភាពនៃវិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការវិវត្តនៃវិមជ្ឈការ និងវិសហមជ្ឈកា និងគោលនយោបាយ និងរាជរដ្ឋាភិបាលកម្ពុជា<br>❑ ស្លាយបង្ហាញអំពីរដ្ឋបាលដែលផ្តល់សេវាដល់ប្រជាពលរដ្ឋ (ការិយាល័យច្រកចេញចូលតែមួយ)<br>❑ ស្លាយបង្ហាញអំពីករណីសិក្សា " ការិយាល័យច្រកចេញចូល តែ១" |

| | កំណែទម្រង់រដ្ឋបាល |
|---|---|
| ឯកសារយោង | ❑ ច្បាប់ និង ប្រកាសនានាដែលទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាន<br>▪ វិសោធនកម្មរដ្ឋធម្មនុញ្ញ<br>▪ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ<br>▪ ប្រកាសស្តីពីតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធអង្គការលេខនៃរដ្ឋបាលខេត្ត និងក្រុង<br>▪ ប្រកាសស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលនៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ សេចក្តីសម្រេចស្តីពីរចនាសម្ព័ន្ធ និងរដ្ឋបាលនៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែ១នៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>▪ ប្រកាសស្តីពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងការិយាល័យប្រជាពលរដ្ឋនៃស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង<br>❑ ក្របខណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>❑ ឯកសារស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា<br>❑ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីគាំទ្រឃុំ-សង្កាត់ |

ចំណុចផ្សេងៗទៀត សម្រាប់ឯកសារ បណ្តុះបណ្តាល

មានចំណុចផ្សេងៗទៀតដើម្បីបង្កើតឯកសារបណ្តុះបណ្តាលឱ្យមានប្រសិទ្ធិភាពៈ (១) ឆាត និងតារាងនានាអាចប្រើប្រាស់បាន (អត្ថបទសៀវភៅ ឯកសារជំនួយនានា និងឯកសារសម្រាប់ចែក) (២) ឯកសារទាំងនោះអាចឱ្យគេរចនាម៉ូដបាន និង(៣) បច្ចេកទេសណែនាំ ។

តារាង និងឆាត

ដើម្បីបង្ហាញព័ត៌មានទាក់ទងទៅនឹងចំនួន មានកត្តាមួយចំនួនដែលចាំបាច់ត្រូវពិចារណាដូចជាៈ ការប្រើប្រាស់កុំព្យូទ័រ ទម្រង់ ឆាត និងស្ថានភាពដែលសមស្របបំផុត ។ មានទម្រង់នៃតារាង និងឆាតដូចខាងក្រោមៈ

**តារាងទី១៦ៈ តារាង និងគំនូសតាងផ្សេងៗ**

| ប្រភេទ | ខ្លឹមសារ |
|---|---|
| តារាង | ❑ គុណសម្បត្តិមានៈ (១) ងាយស្រួលរៀបចំ (២) មានព័ត៌មានច្រើន និង (៣) អាចត្រូវបានគេប្រើប្រាស់ដើម្បីប្រៀបធៀប ។<br>❑ គុណវិបត្តិមានៈ (១) បញ្ចូលព័ត៌មានច្រើនពេក និង (២) ពិបាកក្នុងការកំណត់អ្វីដែលសំខាន់ ។ |
| ខ្សែបន្ទាត់ក្រាភិច | ❑ អាចត្រូវបានគេប្រើសម្រាប់ប្រៀបធៀបទំហំ ។<br>❑ ខ្សែបន្ទាត់នៅលើក្រាភិចអាចនៅជាមួយខ្សែបន្ទាត់ត្រង់ ។<br>❑ វាបង្ហាញនូវ ***ខ្សែបន្ទាត់មួយ ឬ ខ្សែបន្ទាត់ដែលសាកសមបំផុត*** ។ ចូរកត់សំគាល់ថា ខ្សែបន្ទាត់ក្រាភិចអាចផ្តល់ឱ្យអ្នកនូវការកើនឡើងមធ្យមភាគលើគ្រប់ធាតុទាំងអស់ |
| បាឆាត និង ខូឡឹមឆាត (Bar and column charts) | ❑ បាឆាតជាសរសររាងផ្តេក រីឯខូឡឹមឆាតជាសរសររាងឈរ ។<br>❑ ជាទូទៅវាមានន័យថា អ្នកអាចមានសសររាងផ្តេក ច្រើនជាងសរសររាងឈរ តែទោះជាយ៉ាងណាក៏ដោយ គេកម្រប្រើសសរទាំងពីរនេះណាស់<br>❑ វាផ្តល់ព័ត៌មានតិចជាងតារាង ឬក្រាភិច តែផ្តល់នូវឥទ្ធិពលធំធេង |
| ផាយឆាត (Piecharts) | ❑ ខ្សែបន្ទាត់ក្រាភិច និងបាឆាតប្រៀបធៀបទំហំគ្នា ផាយឆាតបង្ហាញនូវសមាមាត្រ<br>❑ វាធ្វើការបែងចែកជាចំណែកៗ ជាទូទៅមិនច្រើនជាង៥ ឬ៦ចំណែកនោះទេ ។ ដើម្បីសង្កត់ធ្ងន់ទៅលើចំណែកណាមួយជាពិសេស គេកាត់ផ្តាច់ចំណែកមួយចេញ ។ |
| អង្គការលេខ (organizational chart) | ❑ វាបង្ហាញនូវទំនាក់ទំនងតាមរយៈខ្សែបន្ទាត់ដាច់ ឬជាប់ ជាធម្មតាវាបង្ហាញនូវទំនាក់ទំនងបន្ទាប់បន្សំ ឬទំនាក់ទំនងរវាងបុគ្គលិក<br>❑ វាមានភាពស្មុគស្មាញ ដូចនេះចៀសវាងប្រើវា លើកលែងតែពេលចាំបាច់ ។ តែពេលប្រើឆាតនេះ គួរដាក់ទំនាក់ទំនងដែលមិនសូវសំខាន់ជាលេខយោង ឱ្យបានសាមញ្ញ |
| ហ្វ្លូឆាត (Flowcharts) | ❑ ឆាតនេះបង្ហាញពីលំហូរនៃសកម្មភាព |

(ប្រភពៈ Stimson (2005). *How to Write and Prepare Training Materials*)

ការពិចារណា
ដែល
ប្រើប្រាស់បាន

កត្តានានាសម្រាប់ពិចារណានៅពេលដែលធ្វើសម្ភារៈបណ្តុះបណ្តាលមានដូចខាងក្រោមនេះៈ

**តារាងទី១៧ៈ ការពិចារណាសម្រាប់ការបង្កើតឯកសារបណ្តុះបណ្តាល**

| ចំណុចនានា | ឃ្លឹមសារ |
|---|---|
| Layout | ❑ ការពិចារណាទៅលើ layout គួរទាក់ទងនឹងកម្រិតបទពិសោធន៍របស់គ្រូ ការគំរាមកំហែងផ្នែកបរិស្ថាន និងគុណភាព ។ |
| លក្ខណៈខាងក្រៅ | ❑ ការពិចារណាទៅលើលក្ខណៈខាងក្រៅទាក់ទងទៅនឹងចម្ងាយនៃការមើលឃើញរបស់ឯកសារ លក្ខខណ្ឌពន្លឺ និង រាងរូវ ឬពណ៌ដែលគេប្រើ ។ |
| ការប្រើប្រាស់ឡើងវិញ | ❑ ការពិចារណាទៅលើការប្រើប្រាស់ឡើងវិញ គេមើលថាតើវគ្គបណ្តុះបណ្តាលត្រូវបានគេផ្តល់ជូនក្នុងទម្រង់តែមួយឬអត់ ។ |
| តម្លៃ | ❑ ការពិចារណាទៅលើតម្លៃ គេមើលទៅលើៈ (១) រយៈពេលនៃភាពអាចប្រើបាននៃឯកសារ (២) ការជួលឧបករណ៍ដើម្បីប្រើប្រាស់ជាមួយឯកសារ (៣) ការសរសេរដែលទាមទារឱ្យមានការបកប្រែទៅជាភាសាមួយទៀត និង (៥) ការធ្វើ Layout ការបោះពុម្ព និងតម្លៃសម្រាប់ផលិតផ្សេងទៀត និងការពិនិត្យឡើងវិញលើខ្លឹមសារ |
| ការចែកចាយ | ❑ ការចែកខ្លឹមសារវគ្គត្រូវតែគិតអំពីការដឹកជញ្ជូន ការគាំទ្រផ្នែកបច្ចេកទេស និងសមត្ថភាពក្នុងការគ្រប់គ្រងរួមមាន ថាតើឧបករណ៍ និង ផលិតផលប៉ុន្មានដែលគេត្រូវការ ។ |
| ការពិនិត្យឡើងវិញ | ❑ ការពិចារណាទៅលើការពិនិត្យឡើងវិញ គេពិនិត្យទៅលើឯកសារបណ្តុះបណ្តាលដែលមានពីមុន ថាតើគួរធ្វើបច្ចុប្បន្នភាពទៅលើឯកសារដែលមាននោះដូចជាការបន្ថែមបន្តិច បន្តួច ឬការប្តូរខ្លឹមសារ ឬក៏មិនបាច់កែប្រែវា ។ |

(ប្រភពៈ Stimson (2005). *How to Write and Prepare Training Materials*)

បច្ចេកទេស បណ្តុះបណ្តាល

មានបច្ចេកទេសបណ្តុះបណ្តាលខ្លះដែលអ្នកគួរចៀសវាង ។

**គំនូសតាងទី១៨ៈ ទង្វើមិនត្រូវធ្វើ**

❑ **កុំឱ្យគ្រូអានឮៗ**

ការអានចេញមកក្រៅឮៗបញ្ជាក់ថា គ្រូមិនបានត្រៀម ហើយក៏បង្ហាញថាមិនគោរពសិទ្ធិអ្នករៀនដែរ លើកលែងតែការអាននោះជាផ្នែកមួយនៃគោលបំណងនៃការរៀន ។

❑ **កុំឱ្យសិស្សអានឮៗ**

វាមិនសមទេក្នុងការដែលឱ្យសិក្ខាកាមអានឮៗ លើកលែងតែការអាននោះទាក់ទងនឹងគោលបំណងនៃការរៀន ។



❑ **កុំចំណាយពេលអានស្ងាត់ៗនៅក្នុងថ្នាក់**

តម្រូវឱ្យមានការអានមុនចូលវគ្គ ។ ប្រសិនបើឯកសារចាំបាច់ឱ្យមានការពន្យល់ គ្រូត្រូវពន្យល់ពីខ្លឹមសារ ។ វិធីសាស្ត្រនេះមិនសូវឱ្យសិក្ខាកាមមានការចូលរួមប៉ុន្មានទេ ។

(ប្រភពៈ Hassell-Corbiell (2001). *Developing Training Courses*)

ការវាយតម្លៃ និងការពិនិត្យ ឡើងវិញ

ការវាយតម្លៃវគ្គបណ្តុះបណ្តាលធ្វើឡើងនៅពេលយើងធ្វើវគ្គបណ្តុះបណ្តាល ។ ព័ត៌មានលម្អិតសម្រាប់វិធីសាស្ត្រវាយតម្លៃនេះមានរៀបរាប់នៅក្នុង" ឯកសារមេរៀនស្តីពីការវាយតម្លៃវគ្គបណ្តុះបណ្តាល" ។ ដូចនេះផ្នែកនេះបង្ហាញតែផ្នែកនៃការពិនិត្យឡើងវិញប៉ុណ្ណោះ ។ ការពិនិត្យឡើងវិញជាដំណើរការនៃការកែតម្រូវកំហុសនានាដូចជាការដាក់លេខរៀងទំព័រ និងអក្ខរាវិរុទ្ធ ការកែសម្រួលពេលវេលា ឬលំដាប់លំដោយ ផ្លាស់ប្តូរដំណើរការដូចជាធ្វើលំហាត់ សំណួរតេស្ត ឧទាហរណ៍ និងធ្វើបច្ចុប្បន្នភាព ឬកែប្រែខ្លឹមសារដូចជាគោលនយោបាយរដ្ឋាភិបាល និងអាទិភាពនានា ។

## ឯកសារយោង:

Frank, Darlene. *Terrific Training Materials: High Impact Graphic Designs*, N.p.: HRD Press, 1996.

Hassell-Corbiell, Rives. *Developing Training Courses: A Technical Writer's Guide to Instructional Design and Development*. Tacoma, Washington: Learning Edge Publishing, 2001.

Nilson, Carolyn. *How to Manage Training: A Guide to Design and Delivery for High Performance*. New York: AMACOM, 2003.

Stimson, Nancy. *How to Write and Prepare Training Materials*. London: Kogan Page, 2005.